ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី៤ ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ



ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## គតិបណ្ឌិតបិតាស្ថាបនិកសន្តិភាពកម្ពុជា

# « កីឡារស់ក្នុងសន្តិភាព »

**សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ពហុកីឡដ្ឋានមរតកតេជោ ថ្ងៃទី ២១ វិច្ឆិកា ២០២២

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ុំ ថុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា
- អ៊ិន តុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- វាចារណកថា កិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ជាទីកន្លែងសុខសាន្ត នៃមេដឹកនាំតំបន់ និងពិភពលោក ១-២

II- បទអត្ថាធិប្បាយ គំនិតវិទ្យាសាស្ត្រ ៣-៥

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ ៦-៧

២- សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ៨-៩

៣- សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២១ - ២០២៥ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧ - ២០៣០ ១០-១១

IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ១២-២០

V- បទវិភាគ៖

១- តើថ្នាក់ដឹកនាំ CPC ថ្មីមានទស្សនៈយ៉ាងណាចំពោះការប្តេជ្ញាចិត្តរបស់ចិនចំពោះពិភពលោក? ២១-២២

២- សហប្រតិបត្តិការយោធាចិន-កម្ពុជា ២៣

៣- ផែនការពង្រីកយោធារបស់ជប៉ុន ២៤-២៥

VI- នាទីសិក្សា-ស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផលនៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣ - ១៩៨៦ ២៦-២៩

VII- នាទីវប្បធម៌

១- ពន្យល់ពាក្យ ៣០

២- ស្វែងយល់ពី ព្រះពុទ្ធអង្គ (BUDDHA) ៣១-៣៣

VIII- នាទីកំណាព្យ

- ចោលកេរ្តិ៍ក្នុងហាង (បទពាក្យ៧) ៣៤

- សាធុការស្នេហ៍ (ពាក្យ៧) ៣៤

IX- នាទីកំសាន្ត

- រឿងមនុស្សលោក ៣៥

# កិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ជាទីកន្លែងសុខសាន្ត នៃមេដឹកនាំតំបន់ និងពិភពលោក

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

នៅតំបន់អាស៊ាននាឆ្នាំ២០២២នេះ កម្ពុជា គឺជាប្រធានអាស៊ានដែលបានទទួលស្វាគមន៍មេដឹកនាំតំបន់ និងពិភពលោក មានដូចជា អគ្គលេខាធិការអង្គការសហប្រជាជាតិ សហគមន៍អឺរ៉ុប មេដឹកនាំប្រទេសជប៉ុន កូរ៉េខាងត្បូង អ៊ុយក្រែន កាណាដា អូស្ត្រាលី នូវែលហ្សេឡង់ រុស្ស៊ី ចិន និងលោកប្រធានាធិបតីមហាអំណាចសហរដ្ឋអាមេរិក លោក Joe Biden ជាដើម ដែលបានធ្វើដំណើរមកចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំពាក់ព័ន្ធកាលពីថ្ងៃទី១០-១៣ ខែវិច្ឆិកា កន្លងមកនេះ គឺបានលើកតម្កើងកិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិយ៉ាងធំធេង និងជាមោទកភាពជាតិខ្មែរទាំងមូល។

ស្ថិតក្នុងអត្ថន័យដ៏ប្រពៃថ្លៃថ្លានេះ អ្វីដែលមតិជាតិ-អន្តរជាតិចាប់អារម្មណ៍ និងកត់សំគាល់ផងដែរនោះគឺនៅថ្ងៃទី១២ខែវិច្ឆិកាក្នុងពេលដែលដំណើរមកដល់របស់លោកប្រធានាធិបតីមហាអំណាចសហរដ្ឋអាមេរិក លោក Joe Biden ចុះពីលើយន្តហោះពិសេសរបស់លោក នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញវេលាម៉ោង៨.៤០នាទីព្រឹកគឺបន្ទាប់ពីបានទទួលនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងរាក់ទាក់ពី សំណាក់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលនៃកម្ពុជា និងមន្ត្រីការទូត អ្នកមុខអ្នកការមហាអំណាចអាមេរិករួចមក គឺ លោក Joe Biden ពុំបានដើរសំដៅចូលក្នុងរថយន្តលោកនោះភ្លាមទេ។ ដោយឆ្លៀតឱកាសនេះ លោកបែរជាដើរសំដៅទៅរកពលរដ្ឋអាមេរិកាំងដែលកំពុងឈរចាំស្វាគមន៍ទទួលលោកយ៉ាងត្រៀបត្រា នៅក្បែរនោះដើម្បីថតរូបអនុស្សាវរីយ៍យ៉ាងសប្បាយរីករាយទៅវិញ។

នេះសបញ្ជាក់ឱ្យឃើញថា លោកប្រធានាធិ-បតីមហាអំណាច មានជំនឿជឿជាក់យ៉ាងមុតមាំអំពីសុខសន្តិភាព និងសុវត្ថិភាពផ្ទាល់ខ្លួននៅកម្ពុជា។ អ្វីដែលកាន់តែច្បាស់ថែមទៀតនោះ នាពេលល្ងាចក្នុងការរៀបចំពិធីលៀងសាយភោជន៍ជូនដល់ថ្នាក់ដឹកនាំប្រមុខរដ្ឋ ប្រមុខរាជរដ្ឋាភិបាលតំបន់ និងពិភពលោក គេឃើញលោកប្រធានាធិបតីអាមេរិក លោក Joe Biden បានដើរមកថតរូបសែលហ្វីជាមួយបងប្អូនខ្មែរដែលមានភារកិច្ចបម្រើកិច្ចការនៅទីនេះប្រកបដោយទឹកមុខញញឹមរួសរាយរាក់ទាក់ចេញពីបេះដូងយ៉ាងសប្បាយរីករាយជាទីបំផុត។

ចំពោះកាយវិការដែលពោរពេញទៅដោយភាពសិទ្ធិស្នាលយ៉ាងសប្បាយរីករាយ របស់មេដឹកនាំពិភពលោកទី១សហរដ្ឋអាមេរិកទាំងនេះបានបង្ហាញដល់មតិជាតិ និងអន្តរជាតិយ៉ាងច្បាស់ថា កិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ជាទីកន្លែងសុខសាន្តនៃមេដឹកនាំតំបន់ និងពិភពលោក។

ផ្តើមចេញពីភាពរីករាយរបស់មេដឹកនាំតំបន់ និងពិភពលោកនៅលើទឹកដីកម្ពុជាដ៏ស្រស់បវរទាំងនេះ ក៏បានញ៉ាំងឱ្យដំណើរការនៃកិច្ចប្រជុំនេះ ប្រព្រឹត្តទៅដោយភាពរលូតរលូន និងទទួលបានលទ្ធផលជាផ្លែផ្កាជោគជ័យយ៉ាងធំធេង ជូនដល់តំបន់ និងពិភព

លោក។ ក្នុងនោះ មេដឹកនាំតំបន់ និងពិភពលោក រួមទាំងលោក Joe Biden ផងដែរ នៅក្នុងជំនួបទ្វេភាគីជាមួយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** គឺសុទ្ធតែបានសម្តែងនូវការអបអរសាទរពីភាពជោគជ័យយ៉ាងត្រចេះត្រចង់នៃកិច្ចប្រជុំកំពូលអាស៊ានលើកនេះ។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២ បានថ្លែងថា មានកត្តាមួយក្នុងចំណោមកត្តានានា ដែលកម្ពុជា ជាប្រធានអាស៊ានបានទទួលជោគជ័យដ៏ត្រចេះត្រចង់ជូនដល់តំបន់ និងពិភពលោកទាំងនេះ ព្រោះក្នុងនាមសម្តេចតេជោ ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជាគឺ " ការអនុវត្តការទូតឯករាជ្យដោយផ្អែកលើច្បាប់ពាក់ព័ន្ធ និងការបោះឆ្នោតនៅអង្គការសហប្រជាជាតិលើបញ្ហារុស្ស៊ី-អ៊ុយក្រែន " ដោយបានប្រកាសជំហរឥតអល់ឯកគាំទ្រអង្គការសហប្រជាជាតិ ដោយចាត់ទុកសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន គឺជាការឈ្លានពានរបស់រុស្ស៊ីទៅលើប្រទេសអ៊ុយក្រែន។

ហេតុនេះហើយលទ្ធផលជោគជ័យ ដែលនាំកម្ពុជាសម្រេចបានក្នុងនាមប្រធានអាស៊ានមានភាពល្បីរន្ទឺខ្ទរខ្ទាលើឆាកអន្តរជាតិនេះគឺបានធ្វើឱ្យមេដឹកនាំអាស៊ាន និងប្រទេសជាដៃគូបានពិភាក្សាលើឯកសារជាច្រើន រហូតបានអនុម័តនូវឯកសារសរុបទាំងអស់ចំនួន១០១ឯកសារ។ នៅក្នុងនោះមានឯកសារសំខាន់ៗជាអាទិ៍ដូចជា៖ សេចក្តីថ្លែងការណ៍ស្តីពីទស្សនវិស័យរបស់ប្រមុខដឹកនាំអាស៊ានលើមូលបទអាស៊ានរួមគ្នាធ្វើការដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា សេចក្តីថ្លែងការណ៍របស់ប្រមុខដឹកនាំអាស៊ាន ស្តីពីខួបទី៥៥នៃអាស៊ាន និងសេចក្តីថ្លែងការណ៍ប្រមុខដឹកនាំអាស៊ានស្តីពីរបៀបវារៈតភ្ជាប់អាស៊ានក្រោយឆ្នាំ២០២៥ ជាដើម។

ក្រៅពីនេះក្នុងឋានៈជាប្រធានអាស៊ានកម្ពុជាក៏បានសម្របសម្រួលឱ្យប្រទេសរហូតដល់ទៅ៧មកចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអគ្នេយ៍គឺអ៊ុយក្រែននៅក្នុងទីក្រុងភ្នំពេញ ក្រោមក្រសែភ្នែកពីប្រទេសចូលរួម២៩ និងស្ថាប័នអន្តរជាតិធំៗ ដោយរួមទាំងអង្គការសហ-ប្រជាជាតិផងដែរ។ ដោយឡែក ក្រោមការប្តេជ្ញាចិត្តរបស់កម្ពុជា ចំពោះទីម័រខាងកើត ក៏បានសម្របសម្រួលហើយមេដឹកនាំអាស៊ានក៏បានឯកភាពទទួលយកទីម័រខាងកើតជាសមាជិកទី១១ របស់អាស៊ាន និងផ្តល់ឋានៈជាប្រទេសសង្កេតការណ៍ដោយអនុញ្ញាតឱ្យទីម័រខាងកើត អាចចូលរួមសកម្មភាពអាស៊ានទាំងអស់។

ដូច្នេះកិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ពិតជាបានបង្ហាញនូវតួនាទីនាំមុខរបស់កម្ពុជាយ៉ាងសកម្មក្នុងនាមជាប្រធានអាស៊ានលើការដោះស្រាយបញ្ហាតំបន់ និងពិភពលោកដ៏ស្មុគស្មាញ និងតានតឹងប្រកបដោយលទ្ធផលជាផ្លែផ្កាជោគជ័យយ៉ាងត្រចេះត្រចង់ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្រ្តរបស់អាស៊ាន។

# គំនិតវិទ្យាសាស្ត្រ ( Esprit Scientifique )

ការរស់នៅរបស់មនុស្សនៅក្នុងសង្គម ដឹកនាំមនុស្សឱ្យស្វែងរកការចម្រើនលូតលាស់ សម្រាប់សេចក្តីត្រូវការរបស់មនុស្សផងគ្នា។ជាការពិតហើយដែលថាមនុស្សតែងតែខ្វល់ខ្វាយជានិច្ចក្នុងការស្វែងរកការចេះដឹងនិងការយល់។ តែមុននឹងក្លាយទៅជាអ្នកប្រាជ្ញ ជាអ្នកទស្សនវិជ្ជា ឬជាអ្វីផ្សេងៗទៀត មនុស្សតែងតែត្រូវការរស់ជាចាំបាច់សិន។ ដើម្បីរស់បាន មនុស្សត្រូវធ្វើយ៉ាងណាឱ្យអំពើទាំងឡាយរបស់ខ្លួន បានទទួលលទ្ធផលជាវិជ្ជមាន។ ដើម្បីសម្រេចគោលបំណងនេះ គេត្រូវដឹងជាមុននូវហេតុផ្សេងៗដែលកើតមានឡើងនៅក្នុងធម្មជាតិដូចជាភ្លៀងខ្យល់ជាដើម។ អាស្រ័យហេតុនេះហើយ បានជាមនុស្សខំស្វះស្វែងរកច្បាប់ទាំងឡាយរបស់ធម្មជាតិ។ ប៉ុន្តែសេចក្តីត្រូវការ និងចំណង់ដឹងតែពីរ ហាក់ដូចជាពុំទាន់គ្រប់គ្រាន់សម្រាប់ពន្យល់អំពីដើមកំណើតរបស់វិទ្យាសាស្ត្របានឡើយ ព្រោះយើងសង្កេតឃើញថាសត្វទាំងអស់សុទ្ធតែរស់ ហើយសុទ្ធតែមានការត្រូវការដែរ តែគ្មានសត្វណាមួយបានក្លាយខ្លួនទៅជាអ្នកប្រាជ្ញសោះ។អាស្រ័យហេតុនេះយើងអាចនិយាយបានថា ដើមកំណើតវិទ្យាសាស្ត្រមិនមែនឋិតនៅត្រង់សេចក្តីត្រូវការ និងចំណង់ដឹងទេ តែឋិតនៅលើការលោភរបស់មនុស្សដែរ។ ដោយមនុស្សដឹងខ្លួនថា គេអាចមានចំណេះលើសនេះទៅទៀត គេអាចធ្វើបានច្រើនទៅទៀតក្នុងខណៈមួយៗ ហើយមនុស្សមានបំណងធំបំផុតនឹងកែប្រែធម្មជាតិ តម្រូវទៅតាមការត្រូវការរបស់ខ្លួនទើបមនុស្សបង្កើតវិទ្យាសាស្ត្រឡើង។

## ក. និយមន័យវិទ្យាសាស្ត្រ

វិទ្យាសាស្ត្រជារបកគំហើញ នៃទំនាក់ទំនងដែលមាននៅក្នុងតថៈ។ វិទ្យាសាស្ត្រស្វែងរកសច្ចៈហេតុនេះហើយបានជាវិទ្យាសាស្ត្រត្រូវលុបចោលនូវពុទ្ធិប្រធានភាពទាំងអស់ ព្រមទាំងការពេញចិត្តផ្ទាល់ខ្លួន។វិទ្យាសាស្ត្រជាការខិតខំ ដើម្បីពន្យល់ និងស្គាល់អ្វីដែលមាន។ និយាយឱ្យងាយស្តាប់ ដំបូងវិទ្យាសាស្ត្រសម្គាល់ចំណេះវិជ្ជាទូទៅដែលមនុស្សត្រូវចេះដឹង និងចំណេះវិជ្ជាទាំងឡាយ ដែលកើតមកពីការស្រាវជ្រាវ។ បន្ទាប់មក វិទ្យាសាស្ត្រសម្គាល់មធ្យោបាយសកម្មសម្រាប់កែប្រែធម្មជាតិ និងត្រួតត្រាលើធម្មជាតិ។ មតិខ្លះថា វិទ្យាសាស្ត្រជាវិធីសម្រាប់ស្វែងរកការពិតទៅវិញ ស្របតាមគំនិតវិទ្យាសាស្ត្រ។

## ខ.បុគ្គលដែលមានគំនិតវិទ្យសាស្ត្រត្រូវប្រកបដោយគុណសម្បត្តិ ២ប្រការៈ

ខ១. គុណសម្បត្តិផ្នែកបញ្ញា : ( qualitiés intellectuelles )

១. ស្រលាញ់សច្ចភាព( amour de vérité ) គឺស្រលាញ់ការពិត និងលះបង់អ្វីដែលជាការភាន់ច្រឡំ បំបាត់អ្វីជាមាយា។ នេះជាគុណសម្បត្តិដ៏ខ្ពង់ខ្ពស់សម្រាប់អ្នកប្រាជ្ញទូទៅនិងអ្នកសិក្សាស្រាវជ្រាវ។

២. ភាពចង់ចេះដឹង ( la curiosité ) គឺភាពពុំព្រងើយកន្តើយ ចូលចិត្តសួរដើម្បីយល់ យល់ដើម្បីចេះ ចេះដើម្បីដឹង។

៣. មានគំនិតរិះគន់ ( esprit critique ) ដែលជាគំនិតមួយពុំសម្របតាមអ្វីទាំងអស់ដែលកើតមានឡើង ពុំទុកចិត្តអ្វីដែលមានន័យត្រឹមតែសំបកក្រៅ ( apparence ) ហើយស្វែងរកអ្វីដែលមានន័យប្រកបដោយប្រាជ្ញាត្រិះរិះល្អិតល្អន់ មានន័យថា គំនិតត្រូវប្រកបដោយសេរីកម្ម ( le libre arbitre ou free will ) ។

៤. មានគំនិតវិជ្ជមាន ( esprit positif ) ដែលជាគំនិតប្រឆាំងនឹងភាពអស្ចារ្យនិងឱ្យតម្លៃលើអ្វីដែលកើតមានឡើង បើមានទើបជឿ បើគ្មានមិនជឿ។

៥.មានគំនិតទទួលស្គាល់ហេតុការណ៍ ( esprit de soumission aux faits ) គឺជាគំនិតទទួលស្គាល់ហេតុការណ៍ណា ដែលកើតមានឡើង

ហើយយកហេតុការណ៍នេះជាប្រភពសម្រាប់ថ្លឹងមើល និងត្រួតត្រាលើពុទ្ធិទាំងអស់។ ឧទាហរណ៍៖ « អ្នកមានប្រាក់ខែតិចចាយពុំគ្រប់គ្រាន់ សុំឱ្យបានឡើងប្រាក់ខែ... រដ្ឋាភិបាលត្រូវពិនិត្យហេតុការណ៍នេះ ហើយត្រូវទទួលស្គាល់ការពិត មិនត្រូវចោទបែបនេះបែបនោះទេគួរពិចារណាខ្លួនឯងមើលបើខ្លួនមានប្រាក់ខែប៉ុណ្ណឹងឱ្យខ្លួនចាយគ្រប់គ្រាន់ទេ? តើអាត្មាអញគត់វាដូចគេដែរឬទេ? បើគេយកគ្រាប់បែកមកគំរាម តើអាត្មាអញភ័យឬទេ? ចំណែកឯអ្នកគត់វាកុំវាប់ឡើងយកធូរធារតែម្ដង គួរត្រូវថ្លឹងថ្លែងទាមទារត្រឹមកម្រិតអប្បរិមានៃការរស់នៅ ( minimum vital ) សិនហើយ។ នេះហើយជាគំនិតទទួលស្គាល់ហេតុការណ៍!

៦. មានជំនឿលើគោលការណ៍ (croyance aux principes) ដូចជាអ្វីៗមានគោលការណ៍ច្បាស់លាស់ មានទ្រឹស្តី មានក្បួន និងទីដៅជាក់លាក់ផ្ទុយពីអ្វីដែលធ្វើដោយចិត្តឯង។ឧទាហរណ៍៖មិនត្រូវយល់ថាវិជ្ជាជីវៈណាមួយប្រសើរជាងគេ ដូចជាគយប្រសើរជាងទាហានទាហានប្រសើរជាងគ្រូគ្រូប្រសើរជាងអ្នកស្រែនោះទេ ត្រូវយល់ថា មុខងារទាំងអស់សុទ្ធតែមានបច្ច័យភាព បើមានមួយខ្វះមួយ ក៏បញ្ហាសង្គមកើតឡើងដែរ។

ខ២. គុណសម្បត្តិផ្នែកសីលធម៌ : (qualités morales)

១.មិនគិតប្រយោជន៍ផ្ទាល់ខ្លួន (esprit de désintéressement)

២.មានគំនិតស្មោះត្រង់នឹងកិច្ចការ (esprit de probité)

៣.មានសេចក្តីក្លាហានជានិច្ច (avoir du courage)

៤.មានគំនិតជាក្រុម (esprit d´équipe) ឧទាហរណ៍៖អត់បាយអត់ទាំងអស់គ្នាមានស៊ីបានស៊ីទាំងអស់គ្នា (ពុំមែនចៅហ្វាយស៊ីទាខ្វៃ អ្នកក្រោមបង្គាប់ស៊ីអំបិលទេ...)

បញ្ជាក់ : កុំច្រឡំគំនិតជាក្រុមនិងគំនិតបក្សពួក (ne pas confondre l´esprit d´équipe avec l´esprit de clan) ពីព្រោះគំនិតបក្សពួក ជាគំនិតគិតយ៉ាងណាឱ្យបក្សពួករបស់ខ្លួនបានខ្ពង់ខ្ពស់ហើយធ្វើឱ្យបក្សពួកអ្នកដទៃវិនាសសាបសូន្យ។

គ.តើវិទ្យាសាស្ត្រអាចធ្វើឱ្យមនុស្សមានសីលធម៌ឬទេ?

មានមតិបីចោទឡើង :

*មតិទី១ : វិទ្យាសាស្ត្រធ្វើឱ្យមនុស្សមានសីលធម៌ដូចម្ដេចខ្លះ?

-ដឹកនាំមនុស្សឱ្យស្រឡាញ់សច្ចភាព គឺស្រឡាញ់ការពិតទូទៅ

-ដឹកនាំមនុស្សឱ្យបណ្តុះគំនិតពិចារណា មិនឱ្យជឿផ្ដេសផ្ដាស

-ដឹកនាំមនុស្សមិនឱ្យលុះតាមដំបូន្មានអ្នកដទៃបានដោយងាយ

-ដឹកនាំមនុស្សឱ្យជឿលើអំពើរបស់ខ្លួន ច្រើនជាងជឿលើព្រះអាទិទេព

-ដឹកនាំមនុស្សឱ្យលះបង់ប្រយោជន៍ផ្ទាល់ខ្លួនព្រោះវិទ្យាសាស្ត្រគ្មានមាតុភូមិទេ ហើយមានគោលដៅដឹកនាំមនុស្សទាំងអស់ទៅរកសេចក្ដីសុខសុខតាមផ្លូវកាយសុខតាមផ្លូវចិត្តសុខតាមផ្លូវសម្ភារៈដូចជាការលូតលាស់នៃវិទ្យាសាស្ត្រសព្វថ្ងៃអាចធ្វើឱ្យមនុស្សយកជ័យជំនះ លើធម្មជាតិបានច្រើន មិនសូវចុះញ៉មធម្មជាតិ។

*មតិទី២:វិទ្យាសាស្ត្រពុំអាចធ្វើឱ្យមនុស្សមានសីលធម៌បានទេ :

-វិទ្យាសាស្ត្រជាមធ្យោបាយធ្វើឱ្យលូតលាស់តាមផ្លូវសម្ភារៈដើម្បីស្វែងរកភោគទ្រព្យ បែរជាឱ្យមនុស្សមានមហិច្ឆតាលោភលន់ពុំចេះចប់បានហើយចង់បានទៀត មានទ្រព្យច្រើន កាន់តែចង់បានច្រើនទៀត។

-វិទ្យាសាស្ត្រជាមធ្យោបាយបម្រើអ្នកមានជាងអ្នកក្រ

-វិទ្យាសាស្ត្រជាមធ្យោបាយសង្កត់សង្កិនអ្នកទន់ខ្សោយគ្រប់ប្រភេទ ក្នុងសកលលោក ដូចជាសំដីរបស់លោក អាលប៊ែរ អាំងស្តាំង (Albert Einstein 1879-1955) រូបវិទូអាល្លឺម៉ង់ថា « ការរីកចម្រើននៃ

វិទ្យាសាស្ត្រ កំហែងគំរាមមនុស្សលោកគួរឱ្យតក់ស្លុត » (le progrès scientifique menace tragiquement l´humanité)

-វិទ្យាសាស្ត្រជាអាវុធមុខពីរ ដែលអាចឱ្យមនុស្សរងគ្រោះច្រើនព្រោះតែមនុស្សយកវិទ្យាសាស្ត្រទៅប្រើ សម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួន។

*មតិទី៣:វិទ្យាសាស្ត្រអាចធ្វើឱ្យមនុស្សមានសីលធម៌ផង និងប្រាសចាកសីលធម៌ផង អាស្រ័យការប្រតិបត្តិ ឬការអនុវត្តៈ

-បើយកវិទ្យាសាស្ត្រទៅប្រើសម្រាប់សេចក្តីសុខ សេចក្តីចម្រើន សេចក្តីត្រូវការរបស់មនុស្សពិតៗ ទើបវិទ្យាសាស្ត្រធ្វើឱ្យមនុស្សមានសីលធម៌

-ផ្ទុយទៅវិញ បើយកវិទ្យាសាស្ត្រទៅប្រើសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនសម្រាប់កំហែងគំរាមអ្នកទន់ខ្សោយ វិទ្យាសាស្ត្រនឹងក្លាយទៅជាអាវុធប្រល័យលោក នឹងក្លាយទៅជាពិសពុលប្រហារជីវិតមនុស្សជាតិ ដូចជាករណីគេយកគ្រាប់បែកទៅប្រើសម្រាប់ប្រហារជីវិតគូសត្រូវ ដើម្បីដោះស្រាយបញ្ហាដែលគេចង់បាន ករណីគ្រូពេទ្យចិញ្ចឹមអ្នកជំងឺ ករណីអ្នកលក់ថ្នាំពេទ្យបន់ស្រន់ឲ្យមនុស្សឈឺច្រើន ... សុទ្ធសឹងជាអំពើអមនុស្សធម៌ខ្លាំងណាស់ ក្បត់សីលធម៌មនុស្សលោក ក្បត់ពាក្យសម្បថរបស់ខ្លួនពេលសិក្សាវេជ្ជសាស្ត្រគឺសម្បថចំពោះអ៊ីប៉ូក្រាត (serment d´Hippocrate) ដែលអប់រំមិនឱ្យគ្រូពេទ្យមានគំនិតជំនួញគ្របដណ្តប់លើគំនិតមនុស្សធម៌។

-ដោយហេតុថា មានមនុស្សយកវិទ្យាសាស្ត្រទៅប្រើក្នុងផ្លូវខុស ប្រាសចាកសីលធម៌ បាត់បង់មនសិការ ទើបលោក Rabelais អ្នកប្រាជ្ញបារាំងសតវត្សទី១៦ បានប្រកាសជាសកលថា « Science sans conscience n´est que ruine de l´âme » មានន័យថា វិទ្យាសាស្ត្រខ្វះមនសិការ ឬខ្វះសីលធម៌ ឬខ្វះការវិនិច្ឆ័យនាំឱ្យវិនាសដល់ព្រលឹងពោលគឺវិនាសដល់មនុស្សទូទៅ ។

-អ្នកប្រាជ្ញខ្លះទៀត អស់សង្ឃឹមលើមហិច្ឆតារបស់មនុស្សដែលចង់បានហើយចង់បានទៀត មិនឈប់ឈរ ព្រោះមនុស្សជាខ្ញុំកញ្ជះនៃសភាវគតិរបស់ខ្លួន (l´homme est esclave de ses instincts) ឬមនុស្សបុថុជ្ជន (l´homme en situation) មុខជាឆ្លៀតយកវិទ្យាសាស្ត្រទៅបង្កើតភោគទ្រព្យរបស់ខ្លួនទើបលោក រូស្សូ (J.J. Rousseau 1712-1778) អ្នកប្រាជ្ញបារាំង ស.វ. ទី១៨ បានប្រឆាំងជាដាច់ខាតនឹងការរីកចម្រើននៃវិទ្យាសាស្ត្រ ហើយរៀបចំមនុស្សឱ្យទៅរស់នៅតាមបែបធម្មជាតិវិញ តាមរយៈស្នាដៃមួយរបស់លោកឈ្មោះ អេមីល (Emile) ។

-នៅសតវត្សទី២០ អ្នកប្រឆាំងនឹងវិទ្យាសាស្ត្រម្នាក់ទៀតឈ្មោះ ហ្សង់ ប៉ូលសាត្រ (Jean Paul Sartre 1905-1980)តាមរយៈស្នាដៃរបស់លោកឈ្មោះសម័យទំនើប (les temps modernes) និងស្នាដៃដទៃទៀតឈ្មោះ ស្ថានភាព (situation 1.2.3.4.5.6.7.8.9...)។

-នៅប្រទេសឥណ្ឌា ប្រសិនបើយើងស្រាវជ្រាវពីសម័យអតីតកាល សាសនាដែលផ្តើមប្រឆាំង នឹងវិទ្យាសាស្ត្រមុនគេ គឺសាសនាជេន ( Jaïnisme ) ព្រោះអ្នកកាន់សាសនានេះ ពុំព្រមប្រើប្រាស់វត្ថុទាំងឡាយដែលកើតឡើងដោយវិទ្យាសាស្ត្រ ឬវត្ថុផលិតចេញពីឧស្សាហកម្ម ហើយយល់ព្រមប្រើប្រាស់ តែវត្ថុទាំងឡាយធ្វើដោយដៃ ព្រមទាំងហាមប្រាមមិនឱ្យឧបាសក និងទេសចរក៍ទាំងឡាយយកប្រដាប់ប្រដាផ្សេងៗ ធ្វើដោយលោហធាតុចូលក្នុងព្រះវិហារជាដាច់ខាត។

ឃ. សន្និដ្ឋាន : វិទ្យាសាស្ត្រអាចធ្វើឱ្យមនុស្សប្រកបដោយសីលធម៌ផង និងប្រាសចាក សីលធម៌ផង អាស្រ័យលើអ្នកប្រើប្រាស់វិទ្យាសាស្ត្រ។យើងពុំប្រឆាំងជាដាច់ខាតនឹងការរីកចម្រើននៃវិទ្យាសាស្ត្រទេ យើងយល់ព្រមទទួលវិទ្យាសាស្ត្រណាដែលដឹកនាំទៅរកការរីកចម្រើន ប្រកបដោយ សីលធម៌ប៉ុន្តែយើងប្រឆាំងនឹងវិទ្យាសាស្ត្រណា ដែលធ្វើឱ្យវិនាសហិនហោចដល់មនុស្សជាតិ។

**ក្រមសីលធម៌ និង គុណធម៌ នៃការរស់នៅ**
**បណ្ឌិតសាស្ត្រាចារ្យ អ៊ុំ ថុង**

## ១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់មន្ទីរពិសោធន៍ជាតិសំណង់

កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **សួន លាងហៃ** និងឯកឧត្តម **ថេន ស៊ីធឿន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព ឯកឧត្តម **ឈួន សុធី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី តាមប្រព័ន្ធ ZOOM ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ មានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ ដើម្បីដឹកនាំ គ្រប់គ្រងការសិក្សា ការស្រាវជ្រាវ និងការពិសោធផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ និងផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់និងបណ្តុះបណ្តាលលើបច្ចេកទេសនិងបច្ចេកវិទ្យាក្នុងវិស័យសំណង់។

សេចក្តីព្រាងអនុក្រឹត្យត្រូវបានរៀបចំឡើងក្នុងបរិការណ៍នៃសន្តិភាពនិងស្ថិរភាពនយោបាយ ហើយដែលវិស័យសំណង់ដើរតួនាទីជាសសរស្តម្ភមួយជាមួយសសរស្តម្ភដែលជំរុញកំណើន ៣ទៀតគឺ វិស័យទេសចរណ៍ វិស័យកសិកម្ម និងវិស័យឧស្សាហកម្ម ដោយចូលរួមរៀបចំនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាំងក្នុងវិស័យសាធារណៈទាំងក្នុងវិស័យឯកជនពិសេសរចនាម្ព័ន្ធផលិតកម្មឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម និងទេសចរណ៍ ព្រមទាំងចូល រួមអភិវឌ្ឍលំនៅឋាន និងសំណង់ផ្សេងទៀតសម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាជនប្រកបដោយសុវត្ថិភាពនិងផាសុកភាព។

រយៈពេលជាងមួយទស្សវត្សរ៍ចុងក្រោយ ទុនវិនិយោគក្នុងវិស័យសំណង់មានកំណើនទៀងទាត់និងនៅតែបន្តរីកចម្រើនជាលំដាប់ ជាពិសេសការសាងសង់សំណង់ធំៗខ្ពស់ៗ ដូចជា អគារស្នាក់នៅរួម អគារលក់ទំនិញ ផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម អគារការិយាល័យ សណ្ឋាគារ អគារពហុមុខងារ សំណង់ទីក្រុងរណប បុរីលំនៅដ្ឋាន ភូមិគ្រឹះ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ធនាគារ រោងចក្រ ឃ្លាំង ស្ថានីយ៍ប្រេងឥន្ធនៈ ។ល។

ក្នុងសន្ទុះនៃការរីកចម្រើនរបស់វិស័យសំណង់ តម្រូវការនៃការពង្រឹងការគ្រប់គ្រងរាល់ដំណើរការនិងប្រតិបត្តិការក្នុងវិស័យសំណង់ និងអ្នកពាក់ព័ន្ធនឹងការងារសំណង់កាន់តែមានភាពចាំបាច់ជាសារវន្ត។ សំណង់កាន់តែធំ កាន់តែខ្ពស់ និងកាន់តែស្មុគស្មាញ កាន់តែទាមទារឱ្យការអនុវត្តបានត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត បច្ចេកវិទ្យា ស្តង់ដារ និងបទប្បញ្ញត្តិបច្ចេកទេស ដើម្បីធានាភាពរឹងមាំ គុណភាព សោភណភាព និងចីរភាពនៃសំណង់ រៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ផង និងដើម្បីលើកតម្កើងអត្តសញ្ញាណជាតិ និងភាពសុខដុមរមនានៅក្នុងសង្គមផង។ឆ្លើយតបនឹងតម្រូវការនេះ រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីសំណង់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការ

ប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់នេះ ត្រូវបានតាក់តែងឡើងដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដើម្បីអនុវត្តមាត្រា២៤ នៃច្បាប់ស្តីពីសំណង់។ សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ និងបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២។

អង្គប្រជុំជំនាញបច្ចេកទេស បានឯកភាពរៀបចំមន្ទីរពិសោធន៍ជាតិសំណង់ឱ្យស្ថិតនៅចំណុះក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានថ្នាក់ស្មើអគ្គនាយកដ្ឋាន និងធ្វើសមាហរណកម្មមន្ទីរសំណង់បច្ចុប្បន្នរបស់ក្រសួងមកក្នុងមន្ទីរពិសោធន៍ជាតិសំណង់នេះ បន្ទាប់ពីអនុក្រឹត្យចូលជាធរមាន។ ចំណុចនេះជាការបង្កើតថ្មីផង ហើយក៏ជាការដំឡើងថ្នាក់ផង គឺធ្វើសមាហរណកម្មមន្ទីរពិសោធន៍ចាស់ថ្នាក់ស្មើនាយកដ្ឋាន មកក្នុងមន្ទីរពិសោធន៍ជាតិសំណង់ថ្មីថ្នាក់ស្មើអគ្គនាយកដ្ឋាន។ ការបង្កើនបន្ទុកចំណាយថវិកា និងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង និងការបង្កើតអង្គភាពថ្មីនេះ តម្រូវឱ្យមានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការមិនទាន់ទទួលបានការឯកភាពជាផ្លូវការពីក្រសួងពាក់ព័ន្ធសំខាន់ទាំងពីរធ្វើឱ្យការប្រជុំអន្តរក្រសួងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ មិនទទួលបានជោគជ័យ ហើយត្រូវលើកមកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ វិញ។ កិច្ចប្រជុំអន្តរក្រសួងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ បានឯកភាពទាំងស្រុងលើសេចក្តីព្រាងដែលបានកែសម្រួលតាមស្មារតីអង្គប្រជុំជំនាញបច្ចេកទេស ក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ បានឯកភាពលើការដំឡើងមន្ទីរពិសោធន៍ពីកម្រិតនាយកដ្ឋានទៅជាមន្ទីរពិសោធន៍ជាតិសំណង់កម្រិតស្មើអគ្គនាយកដ្ឋាន។

សេចក្តីព្រាងអនុក្រឹត្យនេះគ្រោងដាក់សូមហត្ថលេខាពីសម្តេចនាយករដ្ឋមន្ត្រីមុនថ្ងៃបើកដាក់ឱ្យដំណើរការមន្ទីរពិសោធន៍ជាតិសំណង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២។

*ដោយ សួង លាងហៃ (ក.ស.វ. - ក្រុម ១)*

## ២- សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ

ច្បាប់ស្តីពីវិធានដើមកំណើតទំនិញគឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃប្រព័ន្ធច្បាប់នៅលើពិភពលោក ដោយដើរទន្ទឹមគ្នាជាមួយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទ្វេរភាគី តំបន់ និងពហុភាគី។ អនុលោមតាមកិច្ចព្រមព្រៀងស្តីពីវិធានដើមកំណើតទំនិញរបស់អង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងអន្តរជាតិនានា សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ត្រូវបានរៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម។

សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញមានគោលបំណងកំណត់អំពីគោលការណ៍និងវិធានស្តីពីដើមកំណើតទំនិញទាំងទំនិញនាំចេញទាំងទំនិញនាំចូលដើម្បីជម្រុញនិងសម្រួលពាណិជ្ជកម្មដែលទទួលបានផលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនិងចូលរួមក្នុងការបង្ការ ការទប់ស្កាត់ ការគេចវេះ និងការក្លែងបន្លំដើមកំណើតទំនិញចំពោះទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៣ និងទី១៥ ខែកក្កដា ឆ្នាំ២០២២ ដឹកនាំដោយឯកឧត្តម **នរ៉ាណា ឫទ្ធិ អានន្ទជាយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ និងឯកឧត្តម **ស៊ា ម៉ៅ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំដោយមានការចូលរួមពីតំណាង ក្រសួងពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម**ស៊ឹមសុខខេង**រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិងឯកឧត្តម**ចាន់ សុភាព**អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកាក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ គណៈកម្មការភាសាវិទ្យាខ្មែរ និងមន្ត្រីជំនាញពាក់ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រីផង ដែរ។

បន្ទាប់ពីប្រជុំជំនាញបច្ចេកទេស សេចក្តីព្រាងច្បាប់នេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង នៅថ្ងៃទី៩ និងទី១០ ខែសីហា ថ្ងៃទី១ និងទី២ ខែកញ្ញា ឆ្នាំ២០២២ តាមប្រពន្ធអនឡាញ (Zoom) ក្រោមអធិបតីភាព ឯកឧត្តម **គីករ៉េត សំរេច** រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី។ អង្គប្រជុំនេះ មានការចូលរួមពីតំណាង ក្រសួងពាណិជ្ជកម្មដឹកនាំដោយ ឯកឧត្តម **ស៊ឹមសុខខេង**រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិងឯកឧត្តម **ចាន់ សុភាព** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងក្រុមប្រឹក្សាអ្នកច្បាប់ តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឯកឧត្តម លោកជំទាវ តំណាងគ្រប់ក្រសួងស្ថាប័ន តំណាងគណៈកម្មការភាសាវិទ្យាខ្មែរ និងតំណាងនាយកដ្ឋានជំនាញពាក់ព័ន្ធ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

អត្ថប្រយោជន៍នៃសេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញមានដូចខាងក្រោម៖

-កំណត់អំពីគោលការណ៍ និងវិធានដើមកំណើតទំនិញទាំងវិធានដើមកំណើតទំនិញស្ថិតក្រោមប្រពន្ធអនុគ្រោះពាណិជ្ជកម្ម និងទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

-ជាមូលដ្ឋានច្បាប់សម្រាប់អាជ្ញាធរមានសមត្ថ-

កិច្ចចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

-ជួយឱ្យកម្ពុជាអាចបំពេញបាននូវការសន្យារបស់ខ្លួន ក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

-ជួយជម្រុញ និងសម្រួលពាណិជ្ជកម្មដែលទទួលបានផលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

-ជាមធ្យោបាយយ៉ាងមានប្រសិទ្ធិភាពក្នុងការបង្ការ ការទប់ស្កាត់ ការគេចវេះ និងការក្លែងបន្លំដើមកំណើតទំនិញ និងអាចធានាបានថា រាល់ទំនិញនាំចេញពីកម្ពុជាពិតជាមានដើមកំណើតពីកម្ពុជា

-ធានាមិនឱ្យប្រទេសដែលផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដកកម្ពុជាចេញពីបញ្ជីប្រទេសទទួលបានភាពអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី

- រួមចំណែកបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនិងធ្វើឱ្យប្រសើឡើងថែមទៀតនូវសុខមាលភាពសង្គម។

ជារួមសេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញនិងក្លាយជាកម្លាំងចលករក្នុងការជម្រុញលំហូរពាណិជ្ជកម្ម ក្នុងការធានាដើមកំណើតទំនិញរបស់កម្ពុជា ក្នុងការបង្កើនផលប្រយោជន៍សេដ្ឋកិច្ច ការអភិវឌ្ឍន៍ប្រទេសជាតិ លើកកម្ពស់សុខមាលភាពប្រជាជនឱ្យកាន់តែប្រសើឡើងថែមទៀត ជាពិសេសចូលរួមជម្រុញការស្តារឡើងវិញនូវសេដ្ឋកិច្ចរបស់កម្ពុជា ដែលរងផលប៉ះពាល់បណ្តាលមកពីការរាតត្បាតជាសកលនៃជម្ងឺកូវីដ១៩។

*ដោយ ម៉ែន សេស (គ.ស.វ. - ក្រុម ២)*

## គតិបណ្ឌិតគួរចេចាំ : បទព្រហ្មគីតិ

« ... ជនណាចេះរាប់អាន
ពេលព្រួយបោះបង់គ្នា
ប្រាជ្ញលោកឱ្យចៀសវាង
កុំរាប់អោយបានចិត្ត
សង្គ្រោះអ្នកសូមទាន
សង្គ្រោះជនចិត្តស្មើយ

តែពេលមានក្តីសុខជា
ជននោះជាអ្នកទ្រុស្តមិត្ត។
ត្រូវឱ្យវាងលែងជិតស្និទ្ធ
កុំស្និតយកជាគ្នាឡើយ។
គ្រាន់នឹងបានបុណ្យជាត្រើយ
ឥតផលឡើយបានតែទោស។ »

សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ
ព.ស. ២៥១៣ គ.ស. ១៩៧០ - ស្នាព្រះហស្តក្រោយបង្អស់

## ៣- សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២១ - ២០២៥ នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧ - ២០៣០

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។កូនៗមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។ នៅក្នុងសង្គម ប្រពៃណីខ្មែរបានឱ្យតម្លៃខ្ពស់លើការគោរពនិងមើលថែទាំមនុស្សវ័យចាស់ពីព្រោះមនុស្សវ័យចាស់មានតួនាទីសំខាន់ណាស់ក្នុងការកសាងគ្រួសារនិងសហគមន៍ ការអប់រំមនុស្សជំនាន់ក្រោយអំពីទំនៀមទម្លាប់ ប្រពៃណីជាតិសាសនា ការអភិវឌ្ឍភូមិ ឃុំជាដើម។ បន្ថែមពីនេះ មនុស្សវ័យចាស់ជួយសម្រួលការងារគ្រួសារ និងសហគមន៍ ដូចជាការអប់រំគ្រួសារ កូនចៅ ការបង្រៀនចំណេះដឹងទូទៅជំនាញវិជ្ជាជីវៈ ការព្យាបាលជំងឺ ការផ្សះផ្សាវិវាទហិង្សាក្នុងគ្រួសារនិងសហគមន៍ផងដែរ។

យោងតាមជំរឿនទូទៅស្តីពីប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩បានបង្ហាញឱ្យឃើញថា កត្តាប្រជាសាស្ត្រមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ដោយសារតែអត្រាលទ្ធភាពបង្កើតកូនមានការថយចុះ(ថយចុះពី៥,៧ភាគរយនៅឆ្នាំ១៩៩០ មកនៅត្រឹមតែ២,៥ភាគរយនៅឆ្នាំ២០១៩)និងភាពប្រសើរឡើងនៃអាយុសង្ឃឹមរស់មានការកើនឡើង(ពី៥៤ឆ្នាំសម្រាប់បុរស និង៥៨ឆ្នាំសម្រាប់ស្ត្រីនៅឆ្នាំ១៩៩៨ ដល់៧៤,៣ឆ្នាំសម្រាប់បុរស និង៧៦,៨ឆ្នាំសម្រាប់ស្ត្រីនៅឆ្នាំ២០១៩) ដែលជាហេតុនាំឱ្យចំនួនប្រជាជនវ័យចាស់មានការកើនឡើងរហូតដល់ ១ ៣៩៤ ១៤៦នាក់ ស្មើនឹងប្រមាណ ៨,៩ភាគរយនៃចំនួនប្រជាជនសរុប១៥ ៥៥២ ២១១នាក់នៅឆ្នាំ២០១៩។

នៅក្នុងឆ្នាំ២០០២ រាជរដ្ឋាភិបាលបានគាំទ្រសេចក្តីប្រកាសនៃមហាសន្និបាតពិភពលោកលើកទី២ស្តីពីមនុស្សវ័យចាស់នៅទីក្រុងម៉ាឌ្រីដ រួចក៏បានរៀបចំបង្កើតគោលនយោបាយសម្រាប់មនុស្សចាស់ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៣។ ចាប់ពីពេលនោះមក ស្ថានភាពប្រជាសាស្ត្រមានការផ្លាស់ប្តូរយ៉ាងច្រើន ជាពិសេសគឺការប្រែប្រួលពាក់ព័ន្ធនឹងប្រជាជនវ័យចាស់ សំដៅចំពោះប្រជាជនដែលមានអាយុ៦០ឆ្នាំឡើង។ ដោយពិនិត្យឃើញអំពីបញ្ហាប្រឈមនិងតម្រូវការរបស់មនុស្សវ័យចាស់ រាជរដ្ឋាភិបាលបានកែសម្រួលឡើងវិញនូវគោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣ដោយបានប្តូរឈ្មោះទៅជាគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០។ គោលនយោបាយនេះ បានអនុម័តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ខែសីហា ឆ្នាំ២០១៧ ហើយត្រូវបានប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨។

គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់មួយដែលត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាជាច្រើនដែលកំពុងកើតមានពីដំណើរឈានទៅរកវ័យចាស់នៅក្នុងក្របខ័ណ្ឌរួមនៃការអភិវឌ្ឍជាតិ រួមមានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០៣០ និងគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០។គោលនយោបាយនេះ បានកំណត់នូវវិស័យអាទិភាព ៩ : ១-ការធានាឱ្យបាននូវសន្តិសុខហិរញ្ញវត្ថុ។ ២-សុខភាព និងសុខុមាលភាព។ ៣-របៀបរបបនៃការរស់នៅ។ ៤-បរិស្ថានអំណោយផល។ ៥-សមាគមមនុស្សចាស់និងវ័យចាស់សកម្ម។ ៦-ទំនាក់ទំនងអន្តរជំនាន់។ ៧-ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់។ ៨-ស្ថានភាពមានអាសន្ន និង ៩-ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង។គោលនយោបាយ

ជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០ បានកំណត់អំពីទិសដៅនិងយុទ្ធសាស្ត្រសម្រាប់អាទិភាពនីមួយៗ។ ទិសដៅនិងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសកម្មភាពលើកទី២ដែលមានរយៈពេល៥ឆ្នាំ(២០១៧-២០៣០)។ក្រសួងស្ថាប័ននីមួយៗបានតម្រឹមតម្រង់កម្មវិធីអនុកម្មវិធីនិងគម្រោងរបស់ខ្លួនស្របទៅតាមទិសដៅនិងយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០។

ផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ នឹងត្រូវអនុវត្តជា៣ដំណាក់កាល គឺដំណាក់កាលទី១ មានរយៈពេល៣ឆ្នាំ(២០១៨-២០២០) ដំណាក់កាលទី២ មានរយៈពេល៥ឆ្នាំ(២០២១-២០២៥) និងដំណាក់កាលទី៣ មានរយៈពេល៥ឆ្នាំ(២០២៦-២០៣០)។ ផែនការសកម្មភាពឆ្នាំ២០២១-២០២៥ នេះគឺជាលទ្ធផលនៃការពិគ្រោះយោបល់រវាងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ហើយត្រូវប្រើប្រាស់ជាឧបករណ៍ដ៏សំខាន់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សចាស់។ សកម្មភាពចំនួន៣២២នៅក្នុងតារាងម៉ាទ្រិកដើម្បីឆ្លើយតបទៅនឹងអាទិភាព ទិសដៅ និងយុទ្ធសាស្ត្រទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព សម្រាប់អនុវត្តដោយក្រសួងស្ថាប័នចំនួន២៦ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌពេលវេលារបស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០។

សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២១-២០២៥ ត្រូវបានដាក់ប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន២លើក(ថ្ងៃទី២៥ ខែកក្កដានិងថ្ងៃទី១១ខែតុលាឆ្នាំ២០២២)ដឹកនាំដោយសហប្រធាន ឯកឧត្តមបណ្ឌិតសភាចារ្យ **នយ អូន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **សុខ ផេង** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានការចូលរួមរបស់ឯកឧត្តម **អេង ភុកថាយ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាន ឯកឧត្តម **ឃី យ៉ូន** រដ្ឋលេខាធិការ (ប្រជុំលើកទី១) ឯកឧត្តម **ម៉ែន សុចិត្រ** រដ្ឋលេខាធិការ (ប្រជុំលើកទី២) ជាក្រសួងសាមី និងមន្ត្រីជំនាញ ព្រមទាំងមន្ត្រីអង្គភាពពាក់ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី។

ចំពោះសេចក្តីព្រាងដ៏មានសារៈសំខាន់ ក្នុងការបន្តលើកកម្ពស់សុខុមាលភាពមនុស្សវ័យចាស់កម្ពុជានេះ កិច្ចប្រជុំបានយកចិត្តទុកដាក់ពិនិត្យ និងកែសម្រួលជាដំបូងលើផ្នែកទម្រង់ ឱ្យបានសមស្របតាមប្លង់របស់ផែនការសកម្មភាពក្នុងសេចក្តីជូនដំណឹង លេខ៤៣៣ សជណ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ជាមួយនេះ កិច្ចប្រជុំបានពិនិត្យកែសម្រួលលើខ្លឹមសារមួយចំនួនលើតារាងម៉ាទ្រិកដែលមានបរិយាយអំពីសកម្មភាព ចំណុចដៅ សូចនាករ ការលើកគម្រោងថវិកា តាមក្រសួង ស្ថាប័ននីមួយៗ ដែលជាអ្នកអនុវត្តផែនការ និងការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផែនការ។

កិច្ចប្រជុំបានពិភាក្សា និងទុកលទ្ធភាពជូនក្រសួងសាមីធ្វើការបញ្ជាក់បន្ថែមពីក្រសួង ស្ថាប័នពាក់ព័ន្ធ លើចំណុចដៅ សូចនាករក្នុងតារាងម៉ាទ្រិក និងការគ្រោងថវិកាក្នុងផែនការ នៅពេលប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីឱ្យផែនការសកម្មភាពឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០ កាន់តែមានលក្ខណៈជាក់ស្តែងថែមទៀតសម្រាប់ការអនុវត្ត។

*ដោយ ឆាយ ខុម (ក.ស.វ. - ក្រុម ៣)*

# IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ *



ការវិភាគនេះ ត្រូវបានរៀបចំឡើងក្រោយកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃសុក្រ ១០រោច ខែកត្ដិក ឆ្នាំខាល ចត្វាស័កព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្តមទេស-រដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធាន ក.ស.វ. ដែលមានសមាសភាពចូលរួម អនុប្រធានប្រចាំការ អនុប្រធាន ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារក.ស.វ. សមាជិក សមាជិកា ទីប្រឹក្សាបច្ចេកទេសនៃក.ស.វ. ព្រមទាំងអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក មន្ត្រីបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាននៃក.ស.វ. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈប្រព័ន្ធហ្ស៊ូម។ ការវិភាគនេះផ្អែកលើទិន្នន័យព័ត៌មាន ដែលទទួលបានពីក្រសួង ស្ថាប័នពាក់-ព័ន្ធ ព្រមទាំងមតិយោបល់ពីអង្គប្រជុំទាំងមូល។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី៣ ឆ្នាំ២០២២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ ១,០% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៤,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ការដឹកជញ្ជូន | +៧,២% | ប្រេងម៉ាស៊ូត | +៣៨,៥% |
| ភោជនីយដ្ឋាន | +៧,២% | ឧស្ម័ន | +១៦,៧% |
| សំលៀកបំពាក់ និងស្បែកជើង | +៦,៥% | ប្រេងសាំង | +១៣,៦% |
| ការកម្សាន្ត និងវប្បធម៌ | +៦,៣% | ផ្លែឈើ | +៧,៣% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | +៥,១% | បន្លែ | +៧,២% |
| ម្ហូបអាហារ | +៤,៧% | សាច់គោ | +៥,៧% |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +៣,៥% | ត្រីស្រស់ | +៤,៥% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +២,៩% | សាច់មាន់ | +៤,៤% |
| សុខាភិបាល | +១,៧% | សាច់ជ្រូក | +៣,៦% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.២. អត្រាប្តូរប្រាក់

| *បរិយាយ* | *ត្រីមាសទី៣ ២០២២* | *ត្រីមាសទី២ ២០២២* | *ត្រីមាសទី៣ ២០២១* |
|---|---|---|---|
| **៛/ដុល្លារ** | ៤ ១១៩៛/$ | ៤ ០៧០៛/$ | ៤ ០៧៩៛/$ |
| **៛/បាត** | ១០៨៛/បាត | ១១៦៛/បាត | ១២០៛/បាត |
| **៛/ដុង** | ០,១៧៣៛/ដុង | ០,១៧៥៛/ដុង | ០,១៧៩៛/ដុង |
| **បាត/ដុល្លារ** | ៣៨,១បាត/$ | ៣៥,១បាត/$ | ៣៣,៩បាត/$ |
| **ដុង/ដុល្លារ** | ២៣៨២០ដុង/$ | ២៣ ២៤៦ដុង/$ | ២២ ៧៣៥ដុង/$ |
| **យ៉ន់/ដុល្លារ** | ៧,១យ៉ន់/$ | ៦,៧យ៉ន់/$ | ៦,៥យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០២០ ដល់ ២០២២ (ប៊ីលានរៀល)




**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន៥ ៨៧២,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១ ៤៦៨,១លានដុល្លារ (*មធ្យមប្រចាំខែ៩៥,០%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន៥ ៧៧៤,០ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១ ៤៤៣,៥ លានដុល្លារ (*មធ្យមប្រចាំខែ១០៤,២%នៃផែនការ*) និងចំណូលមូលធនចំនួន ៩៨,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ២៤,៦លានដុល្លារ(តាមតួលេខ រតនាគារជាតិ)។

➢ សម្រាប់ត្រីមាសទី៣ឆ្នាំ២០២២នេះ ចំណូលថវិកាជាតិថយចុះ២៧,០% បើធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣៦,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២១។

➢ នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន៦ ០០៣,៤ប៊ីលានរៀលថយចុះ១៩,៩%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣០,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខអគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន៥២០០,០ប៊ីលានរៀលថយចុះ២៥,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣០,៣%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន៥៧៤,០ប៊ីលានរៀលកើនឡើង៣៩,៥% ធៀបនឹងត្រីមាសមុន និងកើនឡើង៩៨,៦%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ** (តួលេខ រតនាគារជាតិ)

| **ចំណូលសារពើពន្ធ** (ក្នុងរង់ក្រចក: បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +៧,០% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៣៩,០%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +៨១៥,៤% | (+០,៤%) |
| ➢ ចំណូលពន្ធដារ: -៣៧,០% (អគ្គនាយកដ្ឋានពន្ធដារ) | (+២២,៩%) | ➢កម្រៃការគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: +១១៣,៧% | (+៨៦,២%) |
| | | ➢សម្បទានរ៉ែ: +០,៧% | (+២៧,៣%) |
| | | ➢អាកាសចរណ៍ស៊ីវិល: +២១១,៦% | (+៣៨៥,៦%) |
| | | ➢ប្រៃសណីយ៍និងទូរគមនាគមន៍: +២៣,៨% | (+២៧៦,២%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន៥ ៤៣៣,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១ ៣៥៨,៣លានដុល្លារ(*មធ្យមប្រចាំខែ៨១%នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន៤ ១៦១,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១ ០៤០,៤លានដុល្លារ(*មធ្យមប្រចាំខែ៨៧% នៃផែនការ*) និងចំណាយមូលធនមានចំនួន១ ២៧១,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៣១៧,៨ លានដុល្លារ(តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០២០ ដល់ ២០២២ (ប៊ីលានរៀល)




➢ចំណាយថវិកាជាតិកើនឡើង៧,៣%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ១៤,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង១២,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ៨,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី៣នេះ មានអតិរេកចំនួន៤៣៩,២ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ១០៩,៨លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី៣ ឆ្នាំ២០២២មានលក្ខណៈដូចខាងក្រោម:

➢ រូបិយវត្ថុ $M_2$ មានចំនួន១៦៩ ៤០៣,៦ ប៊ីលានរៀល មានការកើនឡើង១,៤% ធៀបនឹងខែមុន និងកើនឡើង១០,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង** $M_2$ ក្នុងត្រីមាសនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ ១,០% ។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុត្រីមាសទី៣ ឆ្នាំ២០២២ និង២០២១




➢ក្នុងត្រីមាសនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,៥% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៥% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២២

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៦,៤% | ១៦,៧% | ១៦,៦% | ១៦,៥% | ១៦,១% | ១៥,៩% | ១៦,២% | ១៦,៣% | ១៦,៥% | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៣,៦% | ៨៣,៣% | ៨៣,៤% | ៨៣,៥% | ៨៣,៩% | ៨៤,១% | ៨៣,៨% | ៨៣,៧% | ៨៣,៥% | | | |

ក្រាហ្វ៣.២.បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី៣ ឆ្នាំ២០២២

(ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)



តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំត្រីមាស

| បរិយាយ | ត្រីមាសទី៣ ២០២២ | ត្រីមាសទី២ ២០២២ | ត្រីមាសទី៣ ២០២១ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ១៨៨ ៨៤៩,៩<br>២០ ៥១៣,៣ | ១៨០ ២៨៩,៨<br>១៩ ៨៤៤,១ | ១៥១ ៧០៧,០<br>១៦ ៧២០,១ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ប៊ីលានរៀល) | ៣៧ ៧២៤,៦ | ៣៥ ៧៣០,៤ | ៣៣ ៤១៧,៨ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩% | ៥,៨% | ៤,៣% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៧% | ៤,២% | ៣,៥% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៥% | ១១,០% | ១០,៦% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១០,៨% | ៨,២% | ៨,៦% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៨,០% | ១៧,២% | ១៧,៩% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៥% | ១៧,៦% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,២% | ១៦,៨% | ១៥,៨% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងទេសចរណ៍

➡ក្នុងត្រីមាសទី៣ ឆ្នាំ២០២២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន២០៧,៨ពាន់តោនកើនឡើង១២,០%ធៀបនឹងត្រីមាសមុន និងកើនឡើង១៧,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៣ ៧៣៣,៤GWh មានការថយចុះ១,៥%ធៀបនឹងត្រីមាសមុន ប៉ុន្តែ កើនឡើង១១,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គីសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៣១០៦,៤GWh (ស្មើ៨៣,២%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង៣៩,១%ធៀបនឹងត្រីមាសមុន និងកើនឡើង១៩,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២០៨,១GWh (ស្មើ៥,៦%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៦៥,០%ធៀបនឹងត្រីមាសមុន និងថយចុះ៥៣,៣%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យ(Solar) មានចំនួន១៥៥,៩GWh (ស្មើ៤,២%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៧,៥%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយEDCមានចំនួន២៥២,៩GWh (ស្មើ៦,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៦៤,៥%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១០១,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន១០,១GWh (ស្មើ០,៣%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)មានការថយចុះ៨៧,៨%ធៀបនឹងត្រីមាសមុន និងថយចុះ១២,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ផលិតកម្មស៊ីម៉ង់ត៍មានចំនួន២ ០១៣,១ពាន់តោន មានការថយចុះ៨,៤%ធៀបនឹងត្រីមាសមុន និងថយចុះ១០,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន — ត្រីមាសទី៣ ២០២២* | *ចំនួន—ត្រីមាសទី២ ២០២២* | *ចំនួន—ត្រីមាសទី៣ ២០២១* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៥២ | ៤២ | ៤៦ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៩៦២ | ១ ៩៣៣ | ១ ៨៤៣ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ២៩០ | ១៨៨ | ៣៣៩ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣៥៨ | ២៣១ | ៣៦៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន១ ៩៧២,៣ ពាន់ម$^2$ មានការកើនឡើង២០,០%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ៥៧,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៧៤០,៤លានដុល្លារ មានការកើនឡើង១៥,៦%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ៦០,៧%បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *បរិយាយ* | *ពាន់ម$^2$ — ត្រីមាសទី៣ ២០២២* | *ពាន់ម$^2$ —ត្រីមាសទី២ ២០២២* | *ពាន់ម$^2$ —ត្រីមាសទី៣ ២០២១* |
|---|---|---|---|
| ▪ លំនៅឋាន | ១ ០៦៧,៩ | ១ ០៣៣,០ | ២ ៨៦៥,៧ |
| ▪ ឧស្សាហកម្ម | ៥៦៦,៦ | ៣៩៦,៤ | ៩៣៣,៤ |
| ▪ពាណិជ្ជកម្ម | ១១៩,៧ | ១២៥,៨ | ៥០៨,៣ |
| ▪ ទេសចរណ៍ | ៥,៨ | ៣៤,៦ | ២៦៩,៤ |
| ▪ផ្សេងៗ | ០,០ | ០,០ | ០,០ |
| អនុញ្ញាតសរុប | ១ ៩៧២,៣ | ១ ៦៤៤,០ | ៤ ៦៧៣,៥ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺលំនៅឋាន៥៤,១% និងឧស្សាហកម្ម២៨,៧%នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| *ប្រភេទ* | *ចំនួន — ត្រីមាសទី៣ ២០២២* | *ចំនួន—ត្រីមាសទី២ ២០២២* | *ចំនួន—ត្រីមាសទី៣ ២០២១* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ៣៦០ | ១ ០៩២ | ១ ២៩២ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៣២ | ១៤៧ | ១៦២ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៦៤២ | ១ ៥៦៣ | ១ ៥៩៣ |
| ការស្នើសុំលិខិតអនុញ្ញាត ឬអជ្ញាប័ណ្ណតាមប្រព័ន្ធអេឡិចត្រូនិច | ៦ ២០៧ | ៩ | - |
| ក្នុងនោះ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ៥ ៥៧៧ | ១ | - |

## ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ត្រីមាសទី៣ ២០២២ | នាក់–ត្រីមាសទី២ ២០២២ | នាក់–ត្រីមាសទី៣-២០២១ |
| --- | --- | --- | --- |
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ២ ៦៥៣ | ៥៩៣ | ៧៧៣ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១៥១ ៣៧៨ | ៩៤ ៥៤៥ | ៣៦ ៧៨១ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៤១ ២៦៦ | ៨៧ ២៦៣ | ៣៦ ៤៤៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១០ ១១២ | ៧ ២៨២ | ៣៣៣ |

## ➢ វិនិយោគ

តារាង**៤.៥**.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី៣ ២០២២ | ត្រីមាសទី២ ២០២២ | ត្រីមាសទី៣ ២០២១ |
| --- | --- | --- | --- |
| អនុញ្ញាតសរុប (លានដុល្លារ) | ៤៦០,៨ | ៤៧៨,២ | ៣៨៩,១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ៣៨,៨ | ២៧,៥ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៦១,៥ (១៩៤,៥) | ៤២៦,៧ (៥៩,១) | ២៨៩,៥ (៨២,៧) |
| វិស័យទេសចរណ៍ | ៣៥,៣ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៦៤,០ | ១២,៧ | ៧២,១ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៥២ | ៥១ | ៤៧ |
| បង្កើតការងារ (ពាន់នាក់) | ៤០,៦ | ៣៣,៦ | ៣៥,៥ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ២ ២៧៤,៦ ពាន់តោន មានការថយចុះ២១,៣%ធៀបនឹងត្រីមាសមុននិងមានការថយចុះ១៥,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង**៤.៦**.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
| --- | --- |
| កំពង់ផែភ្នំពេញ: -១៧,២% | (-៣២,៩%) |
| កំពង់ផែកំពង់សោម: -២២,៨% | (-៦,៣%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង**៤.៧**.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន –ត្រីមាសទី៣ ២០២២ | ចំនួន–ត្រីមាសទី២ ២០២២ | ចំនួន–ត្រីមាសទី៣ ២០២១ |
| --- | --- | --- | --- |
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៩៩,៧ | ១២៦,៥ | ៩៦,៦ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ២៣,៧ | ២០,៦ | ១៨,៥ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៦៧៧ | ៧១៤ | ៦២៧ |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២៨,២ | -៤១,៧% | -២២,៩% |
| ក្នុងនោះទទួល | ១០,២ | +៦,៩% | +១២,៩% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៦៨,៨ | -២២,៥% | -៣០,៤% |
| ក្នុងនោះទទួល | ៤៣,៦ | -២៧,២% | -៤៩,៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១ ៦៣៧,១ | -១៦,៤% | -៤៨,១% |
| ក្នុងនោះហៅចូល | ៦៨៦,១ | -២៤,៥% | -៥០,៣% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៤ ០៩១,០ | +១១,៤% | -២១,៥% |
| ក្នុងនោះហៅចូល | ៤ ០២៣,៨ | +១១,៥% | -២១,៣% |

➢ ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១២,២ | +៦៧,៩% | - |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ៧៤,២ | +៨៤,៨% | កើនគំហុគ |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១៤,៩ | -៦០,២% | +៧២៨,២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៨,២ | +៣៤,៤% | កើនគំហុគ |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៧០៣,៩ | +៥៥,៦% | កើនគំហុគ |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស (ពាន់តោន) | ១៣,១ | -៧,៦% | -៤១,៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៣៥៩,៣ | +១៧៧,៤% | កើនគំហុគ |
| ចំនួនទេសចរផ្ទៃក្នុង | ២ ៦៤៧,១ | -៣២,៦% | +៤៥៥,០% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៧៥៩,០ | +១១៨,៦% | កើនគំហុគ |
| ✓ តាមផ្លូវអាកាស | ២២៨,៣ | +៤៨,៥% | កើនគំហុគ |
| ✓ តាមផ្លូវគោក និងទឹក | ៥៣០,៨ | +១៧៤,២% | កើនគំហុគ |

## ៥. ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាត្រីមាសទី៣ ឆ្នាំ២០២២ មានចំនួន ៣០ ៣៩២,៣ ប៊ីលានរៀល (ស្មើនឹង ៧ ៥៩៨,១លានដុល្លារ) ថយចុះ២,៨%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១០,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ ធៀបនឹងត្រីមាសមុន | %∆ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| ប្រេងសាំង | -៤,៦% | +២៨,៦% |
| ប្រេងម៉ាស៊ូត | +៦,០% | -១៣,១% |
| ឧស្ម័ន | +៨,៤% | +២៦,៧% |
| អគ្គិសនីនាំចូលដោយ EDC | -៦៤,៥% | +១០១,៥% |
| ដែកសំណង់ | -១៣,៥% | +១៧,៣% |
| ស៊ីម៉ង់ត៍ | -៥៥,០% | -៤៤,៧% |
| ជីកសិកម្ម | -២៤,៥% | -៣៤,៨% |
| នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | -៥៤,៨% | -៦៩,៩% |
| រថយន្តសរុប (ប៊ី.ល.រ) | +៣២,០% | +៨៤,៦% |
| រថយន្តសរុប (គ្រឿង) | +២៥,៩% | +១០៧,៨% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -២៧,៧% | -២៧,២% |
| ស្រូវសាលី | -២១,៣% | +៤៣,១% |
| អង្ករ | +២២,១% | +៣១,៤% |
| ផ្លែឈើនិងបន្លែ | -៣៨,០% | -៤៤,៧% |
| ថ្នាំកសិកម្ម | -៣៤,៦% | -១,៨% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១៤,៦% | -៧,០% |

➡ **ការនាំចេញ** នាត្រីមាសទី៣ ឆ្នាំ២០២២មានចំនួន**២២ ៩៥៨,៤**ប៊ីលានរៀល ស្មើនឹង**៥ ៧៣៩,៦**លានដុល្លារ ស.រ.អា. (**៧៥,៥**% នៃការនាំចូល) កើនឡើង៨,៤% ធៀបនឹងត្រីមាសមុននិងកើនឡើង៤,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %∆ ធៀបនឹងត្រីមាសមុន | %∆ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| ផលិតផលឈើកែច្នៃ | -៤,១% | -៤៩,២% |
| វាយនភណ្ឌនិងស្បែកជើង | +៩,៨% | +៥,៦% |
| អង្ករ | -២០,៧% | +១,៦% |
| ផលិតផលនេសាទ | +១,២% | -៧,៣% |
| កៅស៊ូ | +២៧,០% | -១០,៥% |

## ១- តើថ្នាក់ដឹកនាំ CPC ថ្មីមានទស្សនៈយ៉ាងណា ចំពោះការប្តេជ្ញាចិត្តរបស់ចិនចំពោះពិភពលោក?

គ្រប់ភ្នែកទាំងអស់ គឺនៅលើប្រទេសចិន ខណៈដែលមេដឹកនាំថ្មីនៃបក្សកុម្មុយនិស្តចិន (CPC) ដែលជាគណបក្សគ្រប់គ្រងលទ្ធិម៉ាក្សនិយមដ៏ធំបំផុតរបស់ពិភពលោកបានបង្ហាញខ្លួនជាលើកដំបូងកាលពីថ្ងៃអាទិត្យនៅទីក្រុងប៉េកាំង។

លោក Xi Jinping បានប្រាប់អ្នកសារព័ត៌មាននៅមហាសាលប្រជាជនថា "ខ្ញុំត្រូវបានជ្រើសរើសជាអគ្គលេខាធិការ CPC ឡើងវិញ" ។

ការបង្ហាញសមាជិកថ្មីចំនួនប្រាំមួយរូបទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិម CPC ទី 20 - Li Qiang, Zhao Leji, Wang Huning, Cai Qi, Ding Xuexiang និង Li Xi - ទៅកាន់អ្នកសារព័ត៌មាន លោក Xi បានប្តេជ្ញាថា ពួកគេនឹងធ្វើការឧស្សាហ៍ព្យាយាមក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនដើម្បីបញ្ជាក់ថា សក្តិសមនៃការទុកចិត្តរបស់បក្សនិងប្រជាជន។

ដោយសង្កត់ធ្ងន់ថា ពិភពលោកកំពុងជួបបញ្ហាប្រឈមដែលមិនធ្លាប់មាន ពីមុនមក លោក Xi បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ប្រទេសចិនចំពោះសហគមន៍ពិភពលោក។ " យើងនឹងធ្វើការជាមួយប្រជាជននៃប្រទេសដទៃទៀតដើម្បីដណ្តើមយកតម្លៃរួមរបស់មនុស្សជាតិ នៃសន្តិភាព ការអភិវឌ្ឍន៍ យុត្តិធម៌ លទ្ធិប្រជាធិបតេយ្យ និងសេរីភាព ដើម្បីការពារសន្តិភាពពិភពលោក និងលើកកម្ពស់ការអភិវឌ្ឍជាសកល ហើយបន្តលើកកម្ពស់ការកសាងសហគមន៍មនុស្សជាមួយនឹងអនាគតរួមគ្នា។" លោក Xi កាលពីថ្ងៃអាទិត្យ បានសង្កត់ធ្ងន់ម្តងទៀតអំពីសារៈសំខាន់ នៃទស្សនវិជ្ជាអភិបាលកិច្ចដែលផ្តោតលើប្រជាជនដែលស្របតាមស្មារតីនៃ CPC ។

លោក Xi បានសង្កត់ធ្ងន់ថា " បក្សគួរតែធ្វើសកម្មភាពដើម្បីប្រជាជនជានិច្ច ហើយពឹងផ្អែកលើប្រជាជនក្នុងដំណើរឆ្ពោះទៅមុខ " ដោយបន្ថែមថា CPC នឹងមិនរងការភ័យខ្លាចដោយខ្យល់បក់ខ្លាំង ទឹកបក់បោក ឬព្យុះដ៏គ្រោះថ្នាក់នោះទេ ត្បិតប្រជាជនតែងតែមានខ្នងបង្អែក ផ្តល់កម្លាំងចិត្ត និងទំនុកចិត្ត។

ក្នុងទស្សវត្សមុននេះក្រៅពីការលុបបំបាត់ភាពក្រីក្រខ្លាំង ប្រទេសចិនបានមើលឃើញពីភាពប្រសើរឡើងជុំវិញជីវិតរបស់ប្រជាជន។

អាយុកាលជាមធ្យមរបស់ប្រទេសចិន បានឈានដល់ 78.2 ឆ្នាំ ប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗរបស់ពួកគេបានកើនឡើងដល់35,100 យន់ (ប្រហែល 4,938 ដុល្លារ) ពី 16,500 យន់ ហើយការងារនៅទីក្រុងជាង13លានត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំជាមធ្យមក្នុងរយៈពេល 10 ឆ្នាំកន្លងមក នេះរបាយការណ៍របស់លោក Xi ទៅកាន់សមាជជាតិ CPC លើកទី 20។

ប្រទេសចិនដែលបានសាងសង់ប្រព័ន្ធអប់រំ សន្តិសុខសង្គម និងថែទាំសុខភាពដ៏ធំបំផុតនៅលើពិភពលោកបានបោះជំហានជាប្រវត្តិសាស្ត្រក្នុងការធ្វើឱ្យការអប់រំមានជាសកលដោយនាំឱ្យមនុស្សចំនួន 1.04 ពាន់លាននាក់ ស្ថិតនៅក្រោមការធានារ៉ាប់រងលើអាយុចាស់ជាមូលដ្ឋាន និងធានាការធានារ៉ាប់រងសុខភាពជាមូលដ្ឋានសម្រាប់ 95 ភាគរយ នៃចំនួនប្រជាជន។

លើសពីនេះ លំនៅឋានជាង 42 លានយូនីតនៅក្នុងតំបន់ទីក្រុងដែលដួលរលំ និងផ្ទះនៅជនបទ

ជាង 24 លានខ្នងត្រូវបានសាងសង់ឡើងវិញ ដែលបណ្តាលឱ្យមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៃលក្ខខណ្ឌលំនៅដ្ឋានទាំងនៅក្នុងទីក្រុង និងជនបទ។

លោក Xi បានសង្កត់ធ្ងន់កាលពីថ្ងៃអាទិត្យថា "ការយកអាទិភាពរបស់ពួកគេជារបស់យើង និងធ្វើតាមបំណងប្រាថ្នារបស់ពួកគេ យើងនឹងបន្តការខិតខំប្រឹងប្រែងដើម្បីប្រែក្លាយសេចក្តីប្រាថ្នាសម្រាប់ជីវិតកាន់តែប្រសើរឡើងឱ្យក្លាយជាការពិត"។ ទំនើបភាវូបនីយកម្មរបស់ចិនដែលជាពាក្យគន្លឹះកំណត់ដំណើររបស់ប្រទេសចិនឆ្ពោះទៅរកការស្តារឡើងវិញជាតិដែលជាពាក្យគន្លឹះនៅក្នុងរបាយការណ៍ ទៅកាន់សមាជជាតិ CPC លើកទី 20 បានជំរុញឱ្យមានការពិភាក្សាយ៉ាងក្តៅគគុកទាំងក្នុងស្រុក និងក្រៅប្រទេស។

វាមានជាគុទូទៅសម្រាប់ដំណើរការទំនើបកម្មនៃប្រទេសទាំងអស់ ប៉ុន្តែសំខាន់ជាងនេះទៅទៀតវាមានបរិបទរបស់ចិន។ដូចដែលរបាយការណ៍បាននិយាយថា វាគឺជាទំនើបកម្មនៃចំនួនប្រជាជនដ៏ច្រើនភាពរុងរឿងរួមសម្រាប់ទាំងអស់គ្នាការរីកចម្រើនខាងសម្ភារៈ និងសីលធម៌ ភាពសុខដុមរមនារវាងមនុស្សជាតិនិងធម្មជាតិ និងការអភិវឌ្ឍន៍ដោយសន្តិភាព។

លោក Xi បានប្រាប់អ្នកសារព័ត៌មានកាលពីថ្ងៃអាទិត្យថា ប្រទេសចិនដែលមានការរីកចម្រើននឹងបង្កើតឱកាសជាច្រើនទៀតសម្រាប់ពិភពលោក។ លោកបានសង្កត់ធ្ងន់ថា ប្រទេសចិននឹងមានភាពខ្ជាប់ខ្ជួនក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅ និងការបើកចំហរទូទាំងក្រុមប្រឹក្សាភិបាល និងក្នុងការបន្តការអភិវឌ្ឍន៍ប្រកបដោយគុណភាពខ្ពស់។

ទិន្នន័យពីការិយាល័យស្ថិតិជាតិ បានបង្ហាញថា ការរួមចំណែកជាមធ្យមរបស់ប្រទេសចិនចំពោះកំណើនសេដ្ឋកិច្ចពិភពលោកមានលើសពី30ភាគរយក្នុងអំឡុងពេល 2013-2021 ដែលជាប់ចំណាត់ថ្នាក់ទីមួយនៅទូទាំងពិភពលោក។

ប្រទេសចិនបានក្លាយជាដៃគូពាណិជ្ជកម្មដ៏សំខាន់សម្រាប់ប្រទេស និងតំបន់ជាង 140 ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ដែលនាំមុខពិភពលោកក្នុងទំហំពាណិជ្ជកម្មសរុបនៃទំនិញ។

ទោះបីជាមានការរាតត្បាតនៃជំងឺកូវីដ-១៩ក៏ដោយ ប្រទេសចិននៅតែបន្តជាស្ថេរភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងឧស្សាហកម្មសកល និងជាកម្លាំងជំរុញនៃការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។ ក្នុងឆ្នាំ 2021 តែមួយ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសចិនមានចំនួន 18.5 ភាគរយ នៃសេដ្ឋកិច្ចពិភពលោក។

ជាងនេះទៅទៀត ដំណើរការទំនើបភាវូបនីយកម្មរបស់ប្រទេសចិនមិនបានចំណាយលើបរិស្ថានទេ។ ប្រទេសនេះ បានកាត់បន្ថយអាំងតង់ស៊ីតេនៃការបំភាយកាបូនរបស់ខ្លួន 34.4 ភាគរយ ក្នុងរយៈពេល10ឆ្នាំចុងក្រោយនេះហើយបានសន្យាថានឹងមានការបំភាយឧស្ម័ន $CO_2$ ខ្ពស់បំផុតមុនឆ្នាំ2030 និងសម្រេចបាននូវអព្យាក្រឹតភាពកាបូនមុនឆ្នាំ 2060។

លោក Xi បាននិយាយថា "ដូចជាប្រទេសចិនមិនអាចអភិវឌ្ឍដោយឯកោពីពិភពលោកបាន ពិភពលោកត្រូវការប្រទេសចិនសម្រាប់ការអភិវឌ្ឍរបស់ខ្លួន" លោក Xi បាននិយាយដោយបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់ប្រទេសចិនថាខ្លួននឹងបើកទ្វារឱ្យកាន់តែទូលំទូលាយទៅកាន់ពិភពលោកទាំងមូល។

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

ប្រភព៖ CGTN

# ២- សហប្រតិបត្តិការយោធាចិន-កម្ពុជា

ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិចិន លោក Wei Fenghe បាននិយាយកាលពីថ្ងៃអាទិត្យថាលោកសង្ឃឹមថាប្រទេសចិននិងកម្ពុជាអាចបង្កើនកិច្ចសហប្រតិបត្តិការយោធាដើម្បីរួមគ្នាការពារសន្តិភាព និងស្ថិរភាពក្នុងតំបន់។

លោកWeiបានអញ្ជើញជួបសំណេះសំណាលជាមួយសម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅរាជធានីភ្នំពេញ។

លោក Wei បាននិយាយថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះយោធាទាំងពីរបានយកឈ្នះលើឥទ្ធិពលនៃជំងឺរាតត្បាត COVID-19 ហើយបានសហការលើផ្នែកនៃការផ្លាស់ប្តូរកម្រិតខ្ពស់ការកសាងយន្តការ សមយុទ្ធ និងការបណ្តុះបណ្តាលរួមគ្នា និងការបណ្តុះទេពកោសល្យ។

រដ្ឋមន្ត្រីក្រសួងការពារជាតិចិនសង្ឃឹមថាយោធាទាំងពីរអាចបន្តធ្វើឱ្យស៊ីជម្រៅ និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ រួមចំណែកកាន់តែច្រើនក្នុងការអភិវឌ្ឍភាពជាដៃគូសហប្រតិបត្តិការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយចិន-កម្ពុជា និងរួមគ្នារក្សាសន្តិភាព និងស្ថិរភាពក្នុងតំបន់។

លោក Wei ក៏បានជម្រាបជូនសម្តេច **ហ៊ុន សែន** អំពីសមិទ្ធផលសំខាន់ៗនៃសមាជជាតិលើកទី២០ នៃបក្សកុម្មុយនិស្តចិន (CPC)។

សម្តេច **ហ៊ុន សែន** អបអរសាទរចំពោះជោគជ័យនៃសមាជជាតិ CPC លើកទី 20 និងចំពោះការបោះឆ្នោតឡើងវិញរបស់ប្រធានាធិបតី Xi ជាអគ្គលេខាធិការនៃគណៈកម្មាធិការកណ្តាល CPC ។

សម្តេចតេជោ ក៏បានថ្លែងអំណរគុណដល់យោធាចិនដែលបានគាំទ្រនិងជួយដល់យោធាកម្ពុជា ហើយសង្ឃឹមថា យោធាទាំងពីរអាចបន្តបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗ។

ដោយសាទរចំពោះសមិទ្ធផលរបស់ប្រទេសចិនក្នុងទសវត្សរ៍កន្លងមកសម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាបានមានប្រសាសន៍ថាប្រទេសចិនក្នុងនាមជាប្រទេសដ៏សំខាន់មួយដែលមានឥទ្ធិពលខ្លាំងលើពិភពលោក រក្សាបាននូវសន្ទុះកើនឡើងដែលមិនឈប់ឈរ។

ថ្លែងក្នុងឱកាសដែលកម្ពុជាកាន់តំណែងជាប្រធានប្តូរវេននៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា ទំនាក់ទំនងអាស៊ាន-ចិន បានឈានដល់កម្រិតខ្ពស់គ្រប់ពេលវេលា ហើយភាគីកម្ពុជាជំរុញយ៉ាងសកម្មក្នុងការចុះហត្ថលេខាលើក្រមកូដនៃការប្រព្រឹត្ត (Code of Conduct) នៅសមុទ្រចិនខាងត្បូង ហើយសង្ឃឹមថានឹងធ្វើការជាមួយចិន ដើម្បីរួមគ្នាការពារសន្តិភាពនិងភាពស្ងប់ស្ងាត់នៅសមុទ្រចិនខាងត្បូង។

**ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត**

ប្រភព៖ CGTN និងដោយមានការបញ្ចូលពី Xinhua

# ៣- ផែនការពង្រីកយោធារបស់ជប៉ុន

ថ្មីៗនេះ រដ្ឋាភិបាលជប៉ុន បានបន្តចាត់វិធានការឆ្ពោះទៅរកការធ្វើយោធាឡើងវិញ។ប្រទេសជប៉ុនកំពុងពិចារណាស្ទើរតែបីដងនៃចំនួនអង្គភាពនៅក្នុងកងកម្លាំងស្វ័យការពាររបស់ខ្លួនដែលបំពាក់ដោយសមត្ថភាព ស្ទាក់ចាប់មីស៊ីលផ្លោងនៅក្នុងប្រជុំកោះភាគនិរតីដាច់ស្រយាលរបស់ប្រទេសនេះនៅចុងឆ្នាំសារពើពន្ធឆ្នាំ២០៣១។

ក្រសួងការពារជាតិជប៉ុន កំពុងពិចារណាបង្កើតក្រុមមួយនៅក្នុងកងកម្លាំងស្វ័យការពារដីដើម្បីការពារប្រជុំកោះ Nansei ដែលរួមមានខេត្ត Okinawa និងផ្នែកខ្លះនៃ Kyushu ភាគខាងត្បូង។

នាយករដ្ឋមន្ត្រីជប៉ុន លោក Fumio Kishida បានណែនាំដល់រដ្ឋមន្ត្រីការពារជាតិ និងហិរញ្ញវត្ថុឱ្យកំណត់ថវិកាប្រមាណ ៤៣ ពាន់ពាន់លាន យ៉េនសម្រាប់ការចំណាយលើវិស័យការពារជាតិ ក្នុងរយៈពេល ៥ ឆ្នាំ ចាប់ពីសារពើពន្ធឆ្នាំ២០២៣។

ទី១:ការយល់ឃើញរបស់សាធារណជនជប៉ុនចំពោះប្រទេសចិនគឺអវិជ្ជមានជាចម្បង។ចិននិងជប៉ុនគឺជាអ្នកជិតខាងដែលមានទំនាក់ទំនងសេដ្ឋកិច្ចវប្បធម៌ និងពាណិជ្ជកម្ម។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសទាំងពីរមានភាពផ្ទុយគ្នាដ៏ស្មុគស្មាញ ដោយសារបញ្ហាប្រវត្តិសាស្ត្រនិងជាក់ស្តែងជាច្រើន។នៅពេលដែលកម្លាំងនិងឥទ្ធិពលរបស់ចិន បន្តកើនឡើងជាមួយនឹងការបញ្ច្រាសនៃតុល្យភាពអំណាច រវាងប្រទេសទាំងពីរនិងការពង្រឹងការប្រកួតប្រជែងជាយុទ្ធសាស្ត្ររបស់សហរដ្ឋអាមេរិកជាមួយប្រទេសចិន ការយល់ឃើញរបស់ជប៉ុនចំពោះប្រទេសចិនកាន់តែអវិជ្ជមាន។

ទី២:សកម្មភាពយោធាភាគច្រើនរបស់ជប៉ុនគឺពាក់ព័ន្ធនឹងចិន ដែលរួមមានវិធានការដូចរៀបរាប់ខាងលើ។ ការបង្កើតក្រុមនៅក្នុងកងកម្លាំងស្វ័យការពារដីគោកគឺដើម្បីពង្រឹងសមត្ថភាពការពាររបស់កងកម្លាំងស្វ័យការពាររបស់ជប៉ុន នៅជិតកោះតៃវ៉ាន់ដូច្នេះ "ប្រសិនបើមានឧបទ្ទវហេតុកើតឡើង" ទីក្រុងតូក្យូអាចឆ្លើយតបនឹងវាបាន។ការពង្រីកកម្លាំងស្ទាក់ចាប់កាំជ្រួចផ្លោងនៅអូគីណាវ៉ា មានគោលបំណងទប់ទល់នឹងការអភិវឌ្ឍន៍អាវុធលឿនជាងសំឡេងដែលជឿនលឿនដោយចិន និងរុស្ស៊ី។

ទី៣ : ការមិនប្រកាន់ចំពោះចិន មិនមែនមានន័យថាប្រឈមមុខជាមួយចិនទេ។ ការយល់ឃើញនិងគោលនយោបាយរបស់រដ្ឋាភិបាលជប៉ុនចំពោះប្រទេសចិន មិនអាចចាត់ទុកថាជាមិត្តនោះទេ ប៉ុន្តែឯកសារផ្លូវការដែលពាក់ព័ន្ធមិនបង្ហាញថាជប៉ុនស្វែងរកការប្រឈមមុខជាមួយចិន ដោយផ្ទាល់នោះទេ។ ហេតុផលជាមូលដ្ឋាន គឺថាទីតាំងអំណាចដែលទាក់ទងគ្នារបស់ចិននិងជប៉ុនត្រូវបានបញ្ច្រាស់ដោយប្រទេសចិនកាន់តែខ្លាំងឡើង និងឆ្ងាយជាងប្រទេសជប៉ុនទាក់ទងនឹងទំហំសេដ្ឋកិច្ចនិងអំណាចយោធា។

ទី៤:យុទ្ធសាស្ត្រសន្តិសុខរបស់ជប៉ុនពឹងផ្អែកលើសម្ព័ន្ធភាពអាមេរិក-ជប៉ុន។ ក្នុងនាមជាប្រទេសដែលចាញ់ក្នុងសង្គ្រាមលោកលើកទីពីរជប៉ុនត្រូវបានដាក់កម្រិតផ្នែកយោធា និងនយោបាយ។ តាម បែបនយោបាយ វាត្រូវបាន "បង្កើត" ដោយសហរដ្ឋអាមេរិក។ ខាងផ្នែកយោធា វាគឺជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក។ ហើយសន្តិសុខរបស់វាក៏ត្រូវបានការពារដោយសហរដ្ឋអាមេរិកផងដែរ។ប្រទេសជប៉ុនបានពឹងផ្អែកលើសម្ព័ន្ធភាពអាមេរិក-ជប៉ុនជាយូរមកហើយ ថាជាមូលដ្ឋានគ្រឹះនៃសន្តិសុខ និងការទូតរបស់ខ្លួន ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះខ្លួនកំពុងស្វែងរកការពង្រឹងអំណាចយោធារបស់ខ្លួន។

ទី៥ : គោលដៅជាមូលដ្ឋានរបស់ជប៉ុន គឺដើម្បីក្លាយជា «ប្រទេសធម្មតា»។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ជាមួយនឹងការងើបឡើងវិញនិងកំណើនសេដ្ឋកិច្ចរបស់ខ្លួន មនោសញ្ចេតនាជាតិ

និយមក្នុងស្រុកបានរីកចម្រើន។ ដូច្នោះហើយវាបានបង្កើតជាបណ្តើរៗនូវគោលដៅយុទ្ធសាស្ត្រជាតិពោលគឺតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ បង្កើតកងទ័ពរបស់ខ្លួន និងផ្លាស់ប្តូររដ្ឋ "សេដ្ឋកិច្ចដ៏ធំ ប៉ុន្តែមនុស្សតឿ" របស់ខ្លួន ហើយចុងក្រោយក្លាយជា "ប្រទេសធម្មតា" ។ គោលដៅនេះ ក៏ត្រូវបានទទួលយកដោយរដ្ឋបាលបច្ចុប្បន្នផងដែរ។

ទី៦:យុទ្ធសាស្ត្រជាក់លាក់របស់ជប៉ុនគឺជំរុញការពង្រីកយោធាដោយបង្កើន"ការគំរាមកំហែងរបស់ចិន"។ រដ្ឋាភិបាលជប៉ុនបានវាយតម្លៃជាអវិជ្ជ- មានចំពោះប្រទេសចិននៅក្នុងយុទ្ធសាស្ត្រសន្តិសុខ ជាតិ គោលការណ៍ណែនាំកម្មវិធីការពារជាតិ និងផែន ការការពារពាក់កណ្តាលអាណត្តិឆ្នាំ២០២១- ២០២៥ ហើយបានបំផុសគំនិត "ការគំរាមកំហែងរបស់ចិន"។ ជារួម វិធីសាស្ត្រនេះ គឺដើម្បីឆ្លៀតឱកាសពង្រឹងការដាក់ពង្រាយយោធារបស់ប្រទេសជប៉ុន និងពង្រឹងអំណាចយោធារបស់ខ្លួន ដើម្បីរៀបចំសម្រាប់ការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រជាតិជាមូលដ្ឋានរបស់ខ្លួន។ និយាយមួយម៉ាត់ ចលនាយោធាថ្មីៗរបស់ជប៉ុន គឺពាក់ព័ន្ធនឹងចិន។

ទោះបីជាយ៉ាងណាក៏ដោយ ខ្លួនមិនស្វែងរកការប្រឈមមុខដាក់គ្នាខាងយោធាដោយផ្ទាល់ជាមួយចិននោះទេ ប៉ុន្តែជាជាងពង្រឹងអំណាចយោធារបស់ខ្លួនតាមរយៈការឃោសនាបំផ្លើស ដូច្នេះវាមិនត្រឹមតែអាចបំពេញតម្រូវការ នៃការដាក់ពង្រាយយុទ្ធ-សាស្ត្ររបស់សហរដ្ឋអាមេរិក ទៅកាន់ប្រទេសចិនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់គោលដៅយុទ្ធ-សាស្ត្រជាតិជាមូលដ្ឋានរបស់ប្រទេសជប៉ុនផងដែរ។

ទោះជាយ៉ាងណាក៏ដោយ សកម្មភាពរបស់ជប៉ុនគឺមិនសមហេតុផល និងមិនអំណោយផលដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់។ ក្នុងនាមជាប្រទេសដែលចាញ់ប្រទេសជប៉ុនបានរក្សាដែនកំណត់ខាងលើនៃថវិកាការពារជាតិប្រចាំឆ្នាំរបស់ខ្លួននៅប្រហែល១ភាគរយនៃផលិតផលក្នុងស្រុកសរុប សម្រាប់រយៈពេលដ៏យូរដែលត្រូវបានចាត់ទុកថា ជាសូចនាករសំខាន់នៃសន្តិភាពរបស់ប្រទេសជប៉ុន។ ប៉ុន្តែរដ្ឋា-ភិបាល Kishida បានសម្រេចចិត្តបង្កើនការចំណាយលើវិស័យការពារជាតិ ដល់ ២ភាគរយ នៃ GDP ឬច្រើនជាងនេះក្នុងរយៈពេល ៥ ឆ្នាំខាងមុខ។

ថវិកាការពារជាតិរបស់ជប៉ុនបានកើនឡើងក្នុងរយៈពេល១០ឆ្នាំជាប់ៗគ្នាហើយជប៉ុនក៏ងាយនឹងបង្កភាពតានតឹងក្នុងតំបន់និងស្វែងរកការទម្លាយផ្នែកយោធាដោយបន្ថែមថាទង្វើដ៏គ្រោះថ្នាក់បែបនេះបានធ្វើឱ្យមានការងឿងឆ្ងល់យ៉ាងខ្លាំងក្នុងចំណោមប្រទេសជិតខាងអាស៊ីនិងសហគមន៍អន្តរជាតិអំពីថាតើជប៉ុនអាចប្រកាន់ខ្ជាប់នូវគោលនយោបាយតម្រង់ទិសការពារទាំងស្រុង និងផ្លូវនៃការអភិវឌ្ឍន៍ដោយសន្តិភាព។

ជប៉ុនគួរតែគិតគូរយ៉ាងម៉ត់ចត់លើប្រវត្តិ នៃការឈ្លានពានរបស់ខ្លួន គោរពការបារម្ភពីសន្តិសុខរបស់ប្រទេសជិតខាងអាស៊ីរបស់ខ្លួននិយាយ និងធ្វើសកម្មភាពដោយប្រយ័ត្នប្រយែងក្នុងវិស័យយោធានិងសន្តិសុខនិងធ្វើអ្វីៗជាច្រើនទៀតដែលអំណោយផលដល់ការរក្សាសន្តិភាព និងស្ថិរភាពក្នុងតំបន់។

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

ប្រភព៖ The Global Times

# ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផល នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦

## ១. សាវតា

នៅពេលដែលពិភពលោក ជាពិសេសបណ្តាប្រទេសនៅអឺរ៉ុបបានចាប់ផ្តើមធ្វើឧស្សាហកម្មនេសាទសមុទ្រនាឆ្នាំ១៨៦០កម្ពុជាក៏បានចាប់ផ្តើមឧស្សាហកម្មនេសាទទឹកសាបរបស់ខ្លួនដែរ អភិវឌ្ឍតែនេសាទសមុទ្រមិនត្រូវបានគេយកចិត្តទុកដាក់ធ្វើការអភិវឌ្ឍន៍ដោយទុកឱ្យវិស័យនេះ ដំណើរការតាមយថាហេតុពីការនេសាទខ្នាតតូចគ្រាន់សម្រាប់ចិញ្ចឹមជីវិតមកត្រឹមនេសាទសិប្បកម្មអស់រយៈជាងកន្លះសតវត្សកន្លងមកនេះ។ជាលទ្ធផលនៃស្ថានភាពនេះព័ត៌មានវិទ្យាសាស្ត្រពាក់ព័ន្ធនឹងសាគរសាស្ត្រ និងធនធានជលផលដែលអាចរកបានក្នុងអំឡុងមុនទសវត្ស៨០មានចំនួនតិចតួចបំផុត ព្រោះថាវិទ្យាស្ថានសាគរសាស្ត្រមួយ ទើបតែបានបង្កើតនៅចុងទសវត្សទី ៦០ ដែលមានអ្នកបច្ចេកទេសមួយចំនួនធ្វើការស្រាវជ្រាវតិចតួចនៅក្បែរច្រាំងទៅតាមមធ្យោបាយ សម្ភារៈឧបករណ៍ដែលខ្វះខាតនៅពេលនោះ ហើយត្រូវបានផ្អាកការងារទាំងស្រុងទៅវិញ នៅឆ្នាំ១៩៧៥ ដោយសារសង្គ្រាម។

ក្រោយរបបកម្ពុជាប្រជាធិបតេយ្យរដ្ឋាភិបាលបានខិតខំខ្នែងស្តារសេដ្ឋកិច្ចជាតិឡើងវិញ ដែលក្នុងនោះវិស័យ ជលផលត្រូវបានចាត់ទុកថាជាមុខព្រួញសេដ្ឋកិច្ចសំខាន់ ក្នុងទិសដៅអភិវឌ្ឍជាមួយដំណាំកៅស៊ូ។ នៅឆ្នាំ១៩៨២ ទន្ទឹមគ្នានឹងការស្តារវិស័យជលផលទឹកសាបឡើងវិញនោះ រដ្ឋាភិបាលក៏បានចាប់អារម្មណ៍ដល់ការអភិវឌ្ឍន៍ជលផលសមុទ្រដែលតម្រូវឱ្យមានព័ត៌មានវិទ្យាសាស្ត្រអំពីធនធាននេះនិងព័ត៌មានពាក់ព័ន្ធគ្រប់គ្រាន់ ដែលអាចជួយដល់ការរៀបចំផែនការអភិវឌ្ឍន៍បាន។ប្រទេសកម្ពុជានៅពេលនោះ មានការខ្វះខាតធនធានមនុស្ស និងព័ត៌មានពាក់ពន្ធនឹងជលផលសមុទ្រស្ទើរតែទាំងស្រុង ដែលតម្រូវឱ្យរដ្ឋាភិបាល លើកសំណើរសុំជំនួយសហប្រតិបត្តិការពីសហភាពសូវៀត នៅឆ្នាំ១៩៨២ ដើម្បីឱ្យមានការស្រាវជ្រាវពីសាគរសាស្ត្រនិងធនធានជលផលសមុទ្រកម្ពុជា ព្រមទាំងសក្តានុពលរបស់វាសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ក្រសួងនេសាទនៃសហភាពសូវៀត បានយល់ព្រមឱ្យវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រសាគរសាស្ត្រ និងជលផល (TINRO) មកធ្វើការស្រាវជ្រាវនៅសមុទ្រកម្ពុជាតាមសំណើររបស់កម្ពុជានៅក្នុងកម្មវិធីស្រាវជ្រាវរយៈពេលបីឆ្នាំ (១៩៨៣-១៩៨៦)។

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រដ៏ធំដែលមិនធ្លាប់មានពីមុនមកនៅកម្ពុជានេះ ត្រូវបានចាត់ទុកថា ជាប្រវត្តិសាស្ត្ររបស់វិស័យជលផលសមុទ្រកម្ពុជា ដែលបានបន្សល់ទុកនូវព័ត៌មានវិទ្យាសាស្ត្រសាគរសាស្ត្រ និងធនធានជលផលសមុទ្រកម្ពុជាជាមូលដ្ឋានសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍វិស័យនេសាទសមុទ្រការអភិរក្សធនធានជលផលនិងសម្រាប់ការស្រាវជ្រាវក្រោយៗទៀត។ការស្រាវជ្រាវវិទ្យាសាស្ត្រពេញលេញដ៏សម្បើមនេះ ត្រូវបានអនុវត្តដោយអ្នកវិទ្យាសាស្ត្រសូវៀតជាច្រើននាក់ និងមន្ត្រីជលផលកម្ពុជា ០៣រូប ចូលរួមក្នុងការងារនៅលើនាវាស្រាវជ្រាវទាំងឡាយ ដែលចូលមកបំពេញការងារនៅសមុទ្រកម្ពុជា។

---

កំណត់ចំណាំៈ ទិន្នន័យ និងព័ត៌មានសំខាន់ៗ ពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រនេះ ត្រូវបានអ្នកនិពន្ធដកស្រង់ចេញពីរបាយការណ៍ Le Rapport General sur les Resultats des Travaux Faites par l' Expedition Sovietique de Pecheries des Recherches Scientifiques a Long Terme Visant a Etudier des Resources Biologiques dans la Zone Economique de la Republique Populaire de Kampuchea de Juin 1983 a Mai 1986 ដោយ INSTITUT SCIENTIFIQUE DE RECHERCHES DE PECHERIES ET D'OCEANOGRAPHIE (TINRO), LE MINISTERE DE PECHERIES DE L'USSR, 1986 អនុវត្តតាមកិច្ចសន្យា N 45 – 051/21400 ចុះថ្ងៃទី ៣១ ឧសភា ឆ្នាំ១៩៨៤។

## ២. សេចក្តីផ្តើម

ប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាជារដ្ឋមានឆ្នេរសមុទ្រ (coastal state) ដែលមានឆ្នេរប្រវែង ៤៣៥គម លាតសន្ធឹងតាមបណ្តោយឆ្នេរ នៃឈូងសមុទ្រថៃ មានព្រំប្រទល់ខាងជើងនិងខាងលិចទល់នឹងសមុទ្រថៃនិងខាងត្បូងទល់នឹងសមុទ្រវៀតណាម និងមានផ្ទៃក្រឡាទំហំ ១៧.២៣៧គម² (FAO, 1991)។សមុទ្រនៅក្រោមយុត្តាធិការកម្ពុជាដែលមានទីតាំងទាំងស្រុងនៅក្នុងឈូងសមុទ្រថៃ ត្រូវបានគេមើលឃើញថា ជាសមុទ្រដែលមានតំបន់ត្រួតស៊ីគ្នាជាច្រើនកន្លែងជាមួយប្រទេសជិតខាង។បញ្ហានេះផ្សំជាមួយភាពសម្បូរបែបនៃត្រីទឹកសាបកាលពីមុនផងនោះ ក៏អាចជាមូលហេតុដែលធ្វើឱ្យការអភិវឌ្ឍន៍នៅសមុទ្រកម្ពុជា មានការយឺតយ៉ាវជាងបណ្តាប្រទេសជិតខាងក្នុងតំបន់។ ជាក់ស្តែង កំពង់ផែសមុទ្រក្រុងព្រះសីហនុត្រូវបានបង្កើត និងដាក់ឱ្យដំណើរការនៅឆ្នាំ១៩៦០ ទន្ទឹមគ្នានឹងការដាក់បញ្ចូលការ ប្រើប្រាស់ម៉ាស៊ីន និងគ្រឿងយន្តទៅក្នុងរបរនេសាទសមុទ្រជាលក្ខណៈសិប្បកម្មដែរ។

នៅពេលដែលពត៌មានពាក់ព័ន្ធនឹងវិទ្យាសាស្រ្តសមុទ្រនិងធនធានធម្មជាតិសមុទ្រមានតិចតួចណាស់សម្រាប់ប្រើប្រាស់ជាមូលដ្ឋាន ក្នុងការរៀបចំគិតគូរអភិវឌ្ឍវិស័យសមុទ្រ ជាពិសេសវិស័យជលផលសមុទ្រ គួបផ្សំនឹងការខ្វះខាតធនធានគ្រប់បែបយ៉ាងនៅក្រោយរបបខ្មែរក្រហមផងនោះការស្រាវជ្រាវវិទ្យាសាស្រ្តសាគរសាស្រ្ត និងធនធានជលផលដ៏ពេញលេញមួយដោយពឹងផ្អែកលើជំនួយពីកិច្ចសហប្រតិបត្តិការអន្តរជាតិ គឺជាតម្រូវការចាំបាច់សម្រាប់អភិវឌ្ឍរាល់វិស័យសមុទ្រ នៅកម្ពុជានាពេលអនាគត។ នៅពេលនោះវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្តសាគរសាស្រ្ត និងជលផល (TINRO) នៃសហភាពសូវៀតដែលធ្លាប់មានបទពិសោធក្នុងការស្រាវជ្រាវសមុទ្រជាច្រើនកន្លែងក្នុងពិភពលោកគឺជាជម្រើសដែលមានអាទិភាពបំផុតសម្រាប់ការសិក្សាស្រាវជ្រាវពីធនធានជលផលសមុទ្រកម្ពុជា។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការព្រមព្រៀងជាបឋម រវាងរដ្ឋមន្ត្រីក្រសួងក្រសួងកសិកម្មកម្ពុជា និងរដ្ឋមន្ត្រីក្រសួងនេសាទសហភាពសូវៀត នាឆ្នាំ១៩៨២ នៅទីក្រុងម៉ូស្គូនៃសហភាពសូវៀត បានសម្រេចថា ឱ្យវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្តសាគរសាស្រ្ត និងជលផលរបស់សហភាពសូវៀត (TINRO) បញ្ជូននាវាស្រាវជ្រាវមកធ្វើការស្រាវជ្រាវអំពីជីវអេកូភូគព្ភសាស្រ្ត នៃបាតសមុទ្រសាគរសាស្រ្ត និងធនធានជលផលនៅទូទាំងសមុទ្រកម្ពុជា ចាប់ពីឆ្នាំ១៩៨៣ តទៅ រហូតដល់ចប់សព្វគ្រប់និងត្រូវផ្តល់របាយការណ៍ពីលទ្ធផលសាវ្រជ្រាវនេះមកឲ្យភាគីកម្ពុជានៅពេលជាបន្ទាប់។

នៅអំឡុងខែកក្កដាឆ្នាំ១៩៨៣នាវាស្រាវជ្រាវរបស់វិទ្យាស្ថាន TINRO នៃសហភាពសូវៀតទីមួយឈ្មោះ Heracklesបានមកចូលចតនៅកំពង់ផែក្រុងព្រះសីហនុប្រទេសកម្ពុជាដែលនៅពេលនោះក្រសួងកសិកម្ម និងនាយកដ្ឋានជលផលកម្ពុជា បានផ្តល់បដិសណ្ឋារកិច្ចដល់ក្រុមអ្នកវិទ្យាសាស្រ្តសូវៀត និងក្រុមនាវិកនៅលើនាវា និងអញ្ជើញប្រធាននាវា និងប្រធានដឹកនាំការស្រាវជ្រាវមកពិភាក្សានៅសាលាក្រុងព្រះសីហនុដើម្បីធ្វើឲ្យដំណើរការស្រាវជ្រាវនៅទូទាំងសមុទ្រកម្ពុជាប្រព្រឹត្តទៅបានដោយរលូនប្រកបដោយជោគជ័យ។ក្នុងការពិភាក្សាគ្នានោះ ភាគីនាយកដ្ឋានជលផលកម្ពុជាបានស្នើរ សុំឲ្យភាគីសូវៀតស្រាវជ្រាវចាប់ពីតំបន់ដែលមានជម្រៅទឹក ២០ម៉ែត្រឡើងទៅនិងសុំឱ្យស្រាវជ្រាវអំពីសត្វគ្មានឆ្អឹងកង (invertebrates)ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ដូចជាបង្គានិងមឹក ជាបន្ថែមទៀត ក្រៅពីនោះគឺការផ្លាស់ប្តូរពត៌មានពាក់ព័ន្ធនឹងសុវត្ថិភាព ដែលនាវាស្រាវជ្រាវត្រូវធ្វើសកម្មភាពតាមទីតាំងស្ថានីយសាគរសាស្រ្តដែលបានកំណត់ពីកន្លែងមួយទៅកន្លែងមួយទៀតនៅក្នុងទូទាំងសមុទ្រកម្ពុជា។ជាមួយគ្នានេះដែរភាគីកម្ពុជាក៏បង្ហាញមន្ត្រីបច្ចេកទេសរបស់ខ្លួនចំនួន០៣រូបដែលត្រូវចូលរួមក្នុងការងារស្រាវជ្រាវនេះ។

## ៤. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំរចនាតាមវិធីសាស្រ្តដែលអាចបកស្រាយបានពី ជលឧតុនិយម (hydrometeorology) ជីវសាស្រ្ត មីក្រូជីវសាស្រ្ត របៀប និងបច្ចេកទេសនៃការធ្វើនេសាទ ការ

ធ្វើអាជីវកម្មនេសាទជាលក្ខណៈសេដ្ឋកិច្ច ធនធានជលផល និងសត្វគ្មានឆ្អឹងកង ជាបីជំហានដែលគ្របដណ្តប់គ្រប់រដូវទាំងអស់នៃឆ្នាំ ស្មើនឹង ៣៦៥នាវា-ថ្ងៃ។ នៅពេលធ្វើការងារជលសាស្ត្រនៅតាមស្ថានីយ៍សាគរសាស្ត្រទាំង ៦៤ទីតាំង ការស្រង់ទិន្នន័យសីតុណ្ហភាពទឹកតាមឧណ្ហមាត្រទៀងទាត់ក្នុងទឹកជ្រៅកំហាប់អំបិលត្រូវបានប៉ាន់ស្មានតាមការវាស់ស្ទង់នៃឧបករណ៍ electric conductibility ទឹកសមុទ្រជំនួយដោយឧបករណ៍វាស់ជាតិអំបិល (salinometer QM-65 និង 601MK 111) កំរិតអុកស៊ីហ្សែនក្នុងទឹកតាមឧបករណ៍ iodometer របស់ Winkler អត្រាសារធាតុជីវពន្ធ (Biogene elements) តាមឧបករណ៍ photoelectrocolorimeter អត្រាហ្វូសហ្វាតតាមវិធីរបស់ Murphy-Rilo និងអត្រាស៊ីលីកា តាមវិធី របស់ Diner និង Van des Bulk ចាប់ពីផ្ទៃលើដល់បាតសមុទ្រនៅគ្រប់សកម្មភាពស្រាវជ្រាវទាំង៣ជំហាន ។

ជំហានទី១ :

-នាវាស្រាវជ្រាវឈ្មោះ HeraKles ទំហំ៨៦ម៉ែត្រជាប្រភេទនាវានេសាទអួនអូសមានបន្ទប់បង្កកត្រី មានបន្ទប់ពិសោធន៍គីមីសាស្ត្រ ជីវសាស្ត្រ ត្រីនិងសត្វសមុទ្រផ្សេងៗ ត្រូវបំពេញការងាររយៈកាល ៨៥ថ្ងៃ (ខែមិថុនា-សីហា ឆ្នាំ១៩៨៣) គិតទាំងថ្ងៃធ្វើដំណើរពីកំពង់ផែវ្លាឌីវ៉ូស្តុក-កម្ពុជា-កំពង់ផែវ្លាឌីវ៉ូស្តុក ដូច្នេះថ្ងៃដែលធ្វើការស្រាវជ្រាវនៅសមុទ្រកម្ពុជាមានតែ៤៨ថ្ងៃប៉ុណ្ណោះ។ នាវា HeraKles នៅពេលនោះ ដោយរៀបចំបង្កើតស្ថានីយន៍ស្រាវជ្រាវចំនួន៦៤ទីតាំង (រូបភាព១) នៅទូទាំងសមុទ្រកម្ពុជាដែលនៅរាល់ស្ថានីយន៍ទាំងនោះត្រូវធ្វើការប្រមូល និងកត់ត្រាទិន្នន័យឧតុនិយម ឧទកសាស្ត្រ (hydrography) ជីវសាស្ត្រ មីក្រូជីវសាស្ត្រ និងធ្វើនេសាទដោយប្រើឧបករណ៍អួនអូសនៅស្រទាប់បាតដើម្បីយកត្រីនិងប្រភេទសត្វផ្សេងៗទៀតមកវិភាគ។

ជំហានទី២ :

-ត្រូវធ្វើការស្រាវជ្រាវរយៈពេល១៣០នាវា-ថ្ងៃ ចាប់ពីខែមិថុនាឆ្នាំ១៩៨៤ ដល់ខែមករាឆ្នាំ១៩៨៥។ ជាក់ស្តែង នាវាស្រាវជ្រាវឈ្មោះ Chantar មានទំហំ




រូបភាព១. ផែនទីបង្ហាញពីតំបន់ និងស្ថានីយ៍ស្រាវជ្រាវ នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-៨៦

ជំហានទី២ :

និងស្ថានភាពលក្ខណៈដូចគ្នានឹងនាវា HeraKles ដែរ ដែលត្រូវបំពេញការងារនៅសមុទ្រកម្ពុជា ចំនួន ៧៧ ថ្ងៃ ចាប់ពីខែឧសភាដល់ខែកក្កដា ឆ្នាំ១៩៨៥។ នាវា Chantar ត្រូវបំពេញការងារប្រមូលទិន្នន័យនៅតាមស្ថានីយន៍ស្រាវជ្រាវទាំង៦៤ទីតាំងដែលបង្កើតឡើងតាមវិធីសាស្ត្រវិទ្យាសាស្ត្រ ដោយនាវា HeraKles ដោយគ្រាន់តែត្រូវយកសំណាកគំរូសាគរសាស្ត្រ សារចុះសារឡើងចំនួន២លើកនៅតាមស្ថានីយ៍និមួយៗ ដោយត្រូវបន្ថែមការធ្វើនេសាទអួនអូសចាប់ត្រីមកវិភាគជាថែមទៀត សម្រាប់ការងារថានានិច្ច័យសាស្ត្រ (taxonomy) ត្រី និងសត្វផ្សេងទៀត និងប្រមូល ទិន្នន័យផលនេសាទដែលចាប់សម្រាប់ប៉ាន់ស្មានផលស្តុកត្រី។

-នាវាឈ្មោះ Ouglekamensk ប្រវែង ៣២ ម៉ែត្រជាប្រភេទនាវានេសាទអួនអូសមានបេសកកម្មតែមួយគត់ គឺធ្វើនេសាទនៅតាមស្ថានីយន៍ស្រាវជ្រាវទាំង ៦៤ទីតាំង ជាច្រើនលើកច្រើនសាររយៈពេល ១២០ថ្ងៃ ពីខែកញ្ញាដល់ខែធ្នូឆ្នាំ១៩៨៥ ដើម្បីការងារថានានិច្ច័យសាស្ត្រត្រី និងសត្វផ្សេងទៀត (Taxaonomy) និងសាកល្បងសមត្ថភាពនិងប្រសិទ្ធិភាព នៃឧបករណ៍អួនអូសដែលរចនាថ្មីនិងប្រមូលទិន្នន័យផលចាប់ សម្រាប់ប៉ាន់ស្មានផលស្តុកត្រី។

ការប្រែប្រួលកាលបរិច្ឆេទស្រាវជ្រាវនៅជំហានទី២នេះគឺបណ្តាលមកពីនាវាឈ្មោះ Ouglekamensk ជួបនូវបញ្ហា នៅពេលចូលមកស្រាវជ្រាវនៅសមុទ្រកម្ពុជានាខែធ្នូឆ្នាំ១៩៨៤ ដោយប្រព័ន្ធគ្រឿងយន្តនៃឧបករណ៍អួនអូសខូច ដែលត្រូវត្រឡប់យកទៅជួស

ជុលវិញ។

ជំហានទី៣ :

-ត្រូវធ្វើការស្រាវជ្រាវរយៈពេល១៣០នាវា-ថ្ងៃ ពីខែមករាដល់ឧសភាឆ្នាំ១៩៨៥។ តែជាក់ស្ដែងនាវាឈ្មោះ Chantar បានមកសកម្មភាពស្រាវជ្រាវនៅសមុទ្រកម្ពុជារយៈពេល៩៩ថ្ងៃ ពីខែមករា ដល់ខែឧសភា ឆ្នាំ១៩៨៦វិញ។ នាវា Chantar ត្រូវបំពេញការងារប្រមូលទិន្នន័យនៅតាមស្ថានីយន៍ស្រាវជ្រាវទាំង ៦៤ទីតាំង ដូចជំហានមុនដែរ និងត្រូវធ្វើច្រំដែលៗជាច្រើនដងតាមស្ថានីយន៍មួយចំនួនជាបន្ថែមទៀត (រូបភាព២) ដើម្បីធ្វើការផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់មុនធ្វើការសន្និដ្ឋានជាចុងក្រោយ។

ជារួម ដំណើររបស់នាវាស្រាវជ្រាវសូវៀតមកធ្វើការនៅសមុទ្រកម្ពុជាទាំង ០៤លើក បានចំណាយពេលអស់ចំនួន ៣៨៤នាវា-ថ្ងៃ ដោយមិនរាប់បញ្ចូលចំនួនថ្ងៃធ្វើដំណើរទៅមករវាងកំពង់ផែវ្លាឌីវ៉ូស្តុកសហភាពសូវៀតនិងកំពង់ផែក្រុងព្រះសីហនុប្រទេសកម្ពុជា ដូចក្នុងតារាងលេខ១ ខាងក្រោម។




រូបភាព ២ : ផែនទីបង្ហាញទីតាំងស្ថានីយ៍ស្រាវជ្រាវផ្ទៀងផ្ទាត់នៅសមុទ្រកម្ពុជា ១៩៨៦

តារាង១ : ប្រភេទ ឈ្មោះ និងរយៈពេលបំពេញការងារនៃនាវាស្រាវជ្រាវ

| ប្រភេទ និង ឈ្មោះនាវា | រយៈពេលបំពេញការងារស្រាវជ្រាវ |
|---|---|
| នាវាអួនអូសមានបន្ទប់ពិសោធន៍ "Herakles" | កក្កដា - សីហា ១៩៨៣ |
| នាវាអួនអូសមានបន្ទប់ពិសោធន៍ "Chantar" | ឧសភា - កក្កដា ១៩៨៥ |
| នាវាអួនអូស "Ouglekamensk" | កញ្ញា - ធ្នូ ១៩៨៥ |
| នាវាអួនអូសមានបន្ទប់ពិសោធន៍ "Chantar" | មករា - ឧសភា ១៩៨៦ |

## ៥. លទ្ធផល

### ៥.១ លក្ខណៈរូប នៃភូមិសាស្ត្រតំបន់ស្រាវជ្រាវនៅសមុទ្រកម្ពុជា

### ៥.១.១ សណ្ឋាន និងរចនាសម្ព័ន្ធនៃបាតសមុទ្រ

តំបន់ស្រាវជ្រាវស្ថិតនៅក្នុងផ្នែកមួយនៃឈូងសមុទ្រថៃដែលមានជំរៅជាមធ្យមប្រមាណ៥០ម៉ែត្រ (ជំរៅជ្រៅបំផុត៨៥ម៉ែត្រ)។ នៅក្នុងចន្លោះជំរៅ២០ម៉ែត្រនិង៣០ម៉ែត្រ បាតសមុទ្រមានលក្ខណៈរាបស្មើជាខ្សាច់លាយជាមួយ កំទិចកំទីតូចៗនៃលាសខ្ចង។ នៅក្នុងចន្លោះជំរៅ៤០ម៉ែត្រ និង៦០ម៉ែត្រ បាតសមុទ្រមានសភាពអង្កាញ់ដូចទឹករលក កោងឡើងចុះពី២ទៅ៤ម៉ែត្រ ហើយនៅកន្លែងខ្លះកោងឡើងដល់១០ម៉ែត្រ គ្របដណ្ដប់ទៅដោយខ្សាច់លាយភក់រលាយបំណែកសំបកលាសខ្ចងធំៗ។នៅក្នុងចន្លោះជំរៅ៦០ម៉ែត្រនិង៧០ម៉ែត្រ បាតសមុទ្រមានលក្ខណៈរាបស្មើជាបង្គួរគ្របដណ្ដប់ទៅដោយភក់រាវស្អិត។នៅភាគខាងលិចឈៀងខាងជើងបាតសមុទ្រគ្របដណ្ដប់ទៅដោយថ្មរងិញរុញ និងភក់រាវស្អិត(រូបភាព៣)។




រូបភាព ៣. ផែនទីបង្ហាញស្ថានភាព និងរចនាសម្ព័ន្ធដីបាតសមុទ្រ

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

## ១- ពន្យល់ពាក្យ

**បដិច្ចសមុប្បាទ** ន. : គឺជាបច្ច័យទាក់ទង ៖

១. អវិជ្ជា = កម្លៅ
២. សង្ខារ = តំណាក់តំណែង
៣. វិញ្ញាណ = ចិត្ត
៤. នាមរូប = នាម និង រូប
៥. សឡាយតនៈ = អាយតនៈ
៦. ផស្សៈ = ការប៉ះពាល់
៧. វេទនា = ទំនួលអារម្មណ៍
៨. តណ្ហា = តម្លាន តម្រេក
៩. ឧបាទាន = សេចក្ដីប្រកាន់មាំ
១០. ភវៈ = ភព
១១. ជាតិ = កំណើត
១២. ជរាមរណៈ = ចំណាស់និងសេចក្ដីស្លាប់

**បញ្ចពិធកល្យាណី** ន. : គឺជាស្ត្រីដែលមានលម្អ ៥ យ៉ាង ៖

១. កេសកល្យាណ = ល្អសក់ រោម
២. មំសកល្យាណ = ល្អសាច់(បបូរមាត់ អញ្ចាញធ្មេញ ផ្ចត់ក កំភួនដៃ ជើង...)
៣. អដ្ឋិកល្យាណ = ល្អឆ្អឹង (ក្រចក ធ្មេញ ម្រាម)
៤. ឆវីកល្យាណ = ល្អសំបុរ
៥. វយកល្យាណ = ល្អវ័យ

**បញ្ចមហាបរិច្ចាគ** ន.:គឺជាការលះបង់ដ៏ឧត្តម៥យ៉ាង របស់ព្រះវេស្សន្តរ ដើម្បីឱ្យបានសម្រេចទាន បារមី ៖

ក. ពាហិរកទាន (អំណោយក្រៅខ្លួន) :

១. ធនបរិច្ចាគ = អំណោយជាទ្រព្យ
២. បុត្តបរិច្ចាគ = អំណោយជាកូន
៣. ទារបរិច្ចាគ = អំណោយជាប្រពន្ធ

ខ. អជ្ឈត្តិកទាន ( អំណោយក្នុងខ្លួន ) :

១. អង្គបរិច្ចាគ = អំណោយជាអវយវៈ នៃរាងកាយ
២. ជីវិតបរិច្ចាគ = អំណោយជាជីវិត

**បន្លែ** ន. : គឺជាស្លឹក ទង ផ្កា ផ្លែ មើមជាដើម សម្រាប់ស្ល។ បន្លែមាន ៖

១. មូលៈ = ឫស
២. បត្តៈ = ស្លឹក
៣. កលីរៈ = ទំពាំង
៤. អគ្គៈ = ត្រួយ
៥. កន្ទៈ = មើម
៦. មិញ្ជៈ = សាច់
៧. ផលៈ = ផ្លែ
៨. តចៈ = សំបក
៩. បុប្ផៈ = ផ្កា
១០. ឆត្តៈ = ផ្សិត

# ២- ស្វែងយល់ពី *ព្រះពុទ្ធអង្គ ( BUDDHA)

-ព្រះពុទ្ធអង្គប្រសូត្រ នៅក្រុងកបិលពស្តុ ក្នុងសួនលុម្ពិនី ទ្រង់មានព្រះនាមថា ព្រះសិទ្ធត្ថ ក្នុងរាជវង្ស គោតម ( Gotama )។

-ព្រះបិតា ព្រះនាម សិរីសុទ្ធោទន៍ ព្រះមាតា ព្រះនាម សិរីមហាមាយា ជាក្សត្រសោយរាជ្យ នៅឥណ្ឌាប៉ែកខាងជើងឈ្មោះ រដ្ឋសាក្យ ឬនេប៉ាល់សព្វថ្ងៃនេះ នាសតវត្សទី៦ មុនគ.ស.។

-បានរៀបអភិសេកជាមួយនាង ពិម្ពាយសោធរា ក្នុងព្រះជន្មាយុ១៦វស្សា ហើយបានរស់នៅក្នុងជីវភាពដ៏ប្រសើរបំផុត។

-បញ្ហាជីវិត បានធ្វើឱ្យទ្រង់យល់ដល់ការឈឺចាប់របស់សត្វលោក។

-ក្នុងព្រះជន្ម ២៩វស្សា ក្រោយពេលបានព្រះរាជបុត្រមួយអង្គ ព្រះនាម រាហុលកុមារមក ព្រះសិទ្ធត្ថកុមារ បោះបង់ចោលរាជសម្បត្តិ ហើយបានយាងចេញទៅសាងផ្នួស។

-ទ្រង់បានយាងទៅសិក្សានិងភិក្ខុជាច្រើនអង្គ ប៉ុន្តែពុំបានសម្រេច។

-ក្នុងព្រះជន្មាយុ ៣៥វស្សា នាល្ងាចមួយ ទ្រង់បានទៅសិក្សាក្រោមដើមពោធិ នៅក្រុងពិហារសព្វថ្ងៃ ទ្រង់បានសម្រេចព្រះសម្មាសម្ពោធិញ្ញាណ ឬការចេះដឹងសព្វគ្រប់។

-ព្រះអង្គ បានយាងទៅប្រោសបញ្ចវគ្គីយ ឬភិក្ខុ៥អង្គ ជាសហការីចាស់ នៅឥសិបតនមិគទាយពន ក្បែរក្រុងពារាណសី។

-ទ្រង់យាងប្រោសសត្វទូទៅ ដោយមិនប្រកាន់វណ្ណៈព្រមទាំងប្រកាសផ្សាយការរំលាយវណ្ណៈទៀតផង។

-ទ្រង់ចូលបរិនិព្វាន ក្នុងព្រះជន្មាយុ ៨០វស្សា នៅក្រុងកុសីនារា ដែលសព្វថ្ងៃហៅឧត្តរប្រទេស ( Uttar Pradesh )។

សង្កេត : សព្វថ្ងៃព្រះពុទ្ធសាសនា មាននៅ ៖ សិរីលង្កា ភូមា ថៃ ខ្មែរ លាវ យួន ទីបេ ចិន ជប៉ុន ម៉ុងគោលី កូរ៉េ ប៉ាគិស្ថាន នេប៉ាល់ និងតៃវ៉ាន់រួមទាំងប្រទេសឥណ្ឌាផ្នែកខ្លះ។រួមទាំងអស់មានពុទ្ធសាសនិកប្រហែលជាង៥០០លាននាក់ ( ស្ថិតិឆ្នាំ១៩៦១ )។

*ទស្សនវិជ្ជាពុទ្ធនិយម : ពុទ្ធសាសនាអាចចាត់ទុកថាជាទស្សនវិជ្ជាក៏បាន ជាធម៌សម្រាប់ប្រតិបត្តិ ដើម្បីរំដោះខ្លួនពីសេចក្តីទុក្ខក៏បាន។ ជាបឋមពុទ្ធសាសនាបង្រៀនឱ្យសម្គាល់ដំណើរចិត្តរួចពន្យល់ពីដំណើរលោករបស់មនុស្សដែលទាក់ទងទៅនឹងការវិលវល់របស់សត្វលោក តាមផ្លូវចិត្តនេះឯង។ ជាពិសេសពុទ្ធសាសនា បានដៅផ្លូវប្រតិបត្តិ ដើម្បីឱ្យមនុស្សយកមកអនុវត្តផ្ទាល់ខ្លួនឯង។តើគោលសំខាន់ដែលព្រះពុទ្ធដៅមក មានអ្វីខ្លះ? ទស្សនវិជ្ជាសំខាន់ដែលព្រះពុទ្ធរកឃើញ គឺទ្រឹស្តីអរិយសច្ចៈ។

I- តើអរិយសច្ចៈជាអ្វី? គឺជាសច្ចៈ គឺការពិតដ៏ខ្ពង់ខ្ពស់។ ព្រះពុទ្ធរកឃើញថា ការពិតសំខាន់ដ៏ខ្ពង់ខ្ពស់មានបួន ហៅថា ចតុរារិយសច្ចៈ រួមមាន៖

ក- ទុក្ខអរិយសច្ចៈ : ជាសេក្តីពិតមួយ គឺថាមានជីវិតពិតជាមានទុក្ខ ពុំអាចចៀសវាងបានឡើយ គ្រាន់តែអ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើនតែប៉ុននោះ។ ទុក្ខ គឺជាសច្ចធម៌ដែលគួរដឹងជាទីបំផុត បានដល់ទុក្ខទាំង ១២កង ដូចតទៅ៖

-ជាតិទុក្ខ គឺទុក្ខកើតពីការកើត

-ជរាទុក្ខ គឺទុក្ខកើតពីសេចក្តីចាស់គ្រាំគ្រា

-ព្យាធិទុក្ខ គឺទុក្ខកើតពីជំងឺរោគាផ្សេងៗ

-មរណទុក្ខ គឺទុក្ខកើតពីសេចក្តីស្លាប់

-សោកទុក្ខ គឺទុក្ខកើតពីការយំស្តាយស្រណោះ

-បរិទេវទុក្ខ គឺទុក្ខកើតពីការខ្សឹកខ្សួល

-ទុក្ខទុក្ខ គឺទុក្ខកើតពីសេចក្តីលំបាកកាយ

-ទោមនស្សទុក្ខ គឺទុក្ខកើតពីសេចក្តីលំបាកចិត្ត

-ឧបាយាសទុក្ខ គឺទុក្ខកើតពីសេចក្តីចង្អៀតចង្អល់ចិត្ត អស់សង្ឃឹម

-អប្បិយេហិ សម្បយោគទុក្ខ គឺទុក្ខកើតពីការជួបនឹងវត្ថុ រឺសត្វមិនជាទីស្រលាញ់

-បិយេហិ វិប្បយោគទុក្ខ គឺទុក្ខកើតពីការព្រាត់ប្រាសវត្ថុ រឺសត្វជាទីស្រលាញ់

-យម្បិច្ឆំ ន លភតិ តម្បិទុក្ខ គឺទុក្ខកើតពីការមិនបានដូចបំណង...។

ខ- សមុទយអរិយសច្ចៈ : ជាសេចក្តីពិតមួយ គឺថាទុក្ខរបស់មនុស្សពិតជាមានហេតុ។ ហេតុសំខាន់មានពីរ គឺតណ្ហា រឺលំងប់ (Passion) និងអវិជ្ជា (Ignorance)។

គ- និរោធអរិយសច្ចៈ : ជាសេចក្តីពិតមួយ គឺថា ទុក្ខពិតជាអាចរំលត់ទៅវិញបាន។ គេបំបាត់ទុក្ខដោយគាស់រំលើងហេតុរបស់ទុក្ខ គឺបំបាត់តណ្ហា និងអវិជ្ជានេះឯង។

ឃ- មគ្គអរិយសច្ចៈ : ជាសេចក្តីពិត គឺថាទុក្ខអាចរំលត់ទៅវិញ តាមផ្លូវរឺមធ្យោបាយត្រូវ។ ព្រះពុទ្ធបានកំនត់យកផ្លូវកណ្តា(មជ្ឈិមាបដិបទា) ដោយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវមគ្គៈ ៨យ៉ាង ដែលគេហៅថា អដ្ឋង្គិកមគ្គ រឺអរិយមគ្គមាន ៖

១-សម្មាទិដ្ឋិ គឺការយល់ឃើញក្នុងផ្លូវត្រូវ

២-សម្មាសង្កប្បៈ គឺការត្រិះរិះក្នុងផ្លូវត្រូវ

៣-សម្មាវាចា គឺសំដីត្រឹមត្រូវ

៤-សម្មាកម្មន្តៈ គឺការប្រព្រឹត្តតែអំពើត្រឹមត្រូវ

៥-សម្មាអាជីវៈ គឺការចិញ្ចឹមជីវិតក្នុងផ្លូវត្រូវ

៦-សម្មាវាយាមៈ គឺការព្យាយាមក្នុងផ្លូវត្រូវ

៧-សម្មាសតិ គឺការរំលឹកខ្លួនឱ្យផ្ចង់ស្មារតីត្រឹមត្រូវ

៨-សម្មាសមាធិ គឺការធ្វើសមាធិត្រឹមត្រូវ

ទ្រឹស្តីសំខាន់មួយទៀត គឺទ្រឹស្តីកម្មផល។

II- តើកម្មផលក្នុងលទ្ធិពុទ្ធសាសនាមានន័យដូចម្តេចខ្លះ ? តាមទស្សនៈពុទ្ធនិយម សត្វលោកតែងវិលកើតវិលស្លាប់មិនចេះចប់ក្នុងវដ្តសង្សារ។ មានជីវិតរមែងជួបប្រទះនឹងទុក្ខសោក រោគាព្យាធិ សេចក្តីលំបាក ហើយកើតមកតែងចាស់ ឈឺស្លាប់ទៅវិញ។ តាមពុទ្ធលទ្ធិភាវៈកើតឡើងខ្លួនឯងតាមកំនត់ច្បាប់ធម្មជាតិ។ ធាតុដែលនាំឱ្យកើតឬស្លាប់ គឺខន្ធទាំង ៥ ហៅថា បញ្ចក្ខន្ធ រួមមាន ៖

១-រូបក្ខន្ធ

២-វេទនាខន្ធ

៣- សញ្ញាខន្ធ

៤-សង្ខារខន្ធ

៥-វិញ្ញាណក្ខន្ធ បានសេចក្តីថា ជាការរួមផ្តុំផ្សំភាវៈទាំងឡាយ។ ភាវៈមានកំណើត ហើយធំធាត់រួចទ្រុឌទ្រោមទៅវិញ រួចធាតុក៏ផ្តុំផ្សំជាថ្មីកើតជាជីវិតថ្មីមួយទៀត។ ដូចនេះ ជីវិតថ្មីមានជាប់ទាក់ទងទៅនឹងជីវិតចាស់ ចំណែកឯកំលាំងអន្ទោលចុះឡើងពីជីវិតមួយទៅជីវិតមួយ គឺកម្មផល។

III- កម្មផលជាអ្វី? កម្មមានន័យថា អំពើផលជាផ្លែលេចចេញពីអំពើ។ ដូច្នេះ តាមទស្សនៈពុទ្ធនិយម ផលល្អ ឬអាក្រក់ បានមកពីការកសាងរបស់ខ្លួន ពុំមែនមកពីអាទិទេពទេ។ អំពើល្អ និងអំពើអាក្រក់ពុំអាចកាត់សងគ្នាបានឡើយ។ បានសេចក្តីថា អំពើអាក្រក់ផ្តល់ផលអាក្រក់ អំពើល្អផ្តល់ផលល្អ បើអំពើល្អផង អាក្រក់ផង នោះផលក៏ត្រូវល្អផង អាក្រក់ផងដែរ ។ និយាយរួមទ្រឹស្តីកម្មផល ជាទ្រឹស្តីទំនាក់ទំនង

ហេតុផល។ទ្រឹស្តីនេះព្រះពុទ្ធបានពន្យល់ក្បោះក្បាយ ហើយដាក់ឈ្មោះថា ទ្រឹស្តីបដិច្ចសមុប្បាទ។

IV- បដិច្ចសមុប្បាទជាអ្វី? គឺជាធម្មភាពភ្ជាប់ហេតុទៅនឹងផល(Loidecausalité)។ភាវៈទាំងអស់ដែលកើតឡើងសុទ្ធតែមានបច្ច័យទាក់ទងគ្នា បើនេះមាននោះក៏មានបើនេះគ្មាននោះក៏គ្មាន។ដំនើរវិលកើតវិលស្លាប់របស់មនុស្សទ្រឹស្តីបដិច្ចសមុប្បាទ បានប្រទាក់គ្នាជាកំរងច្រវាក់នូវហេតុ ១២យ៉ាងគឺ៖

១-អវិជ្ជា(Ignorance) ជាបច្ច័យឱ្យកើតសង្ខារ (Formation)

២-សង្ខារ ជាបច្ច័យឱ្យកើតវិញ្ញាណ (Conscience)

៣.វិញ្ញាណ ជាបច្ច័យឱ្យកើតនាមរូប (Mentalité & Physique)

៤-នាមរូប ជាបច្ច័យឱ្យកើតអាយតនៈ(Sens)

៥-អាយតនៈ ជាបច្ច័យឱ្យកើតផស្សៈ (Contact sensoriel)

៦- ផស្សៈ ជាបច្ច័យឱ្យកើតវេទនា (Sensation)

៧-វេទនាជាបច្ច័យឱ្យកើតតណ្ហា (Désir)

៨-តណ្ហា ជាបច្ច័យឱ្យកើតឧបាទាន (Attachement)

៩-ឧបាទាន ជាបច្ច័យឱ្យកើតភព(Existence)

១០-ភព ជាបច្ច័យឱ្យកើតជាតិ (Naissance)

១១-ជាតិ ជាបច្ច័យឱ្យកើតជរា (Vieillesse)

១២-ជរាជាបច្ច័យឱ្យកើតមរណៈ (Mort)

បើធាតុណាមួយកើតឡើង ធាតុដទៃក៏មានកំនើតជាបន្តបន្ទាប់រហូតដល់មរណៈ។ទ្រឹស្តីសំខាន់មួយទៀតដែលប្រតិកម្មប្រឆាំងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍ក្នុងសម័យព្រាហ្មណ៍និយមគឺទ្រឹស្តីអនត្តៈរឺអនាត្ម័ន។ក្នុងសម័យព្រាហ្មណ៍និយមគេជឿថាព្រះព្រហ្មជាទេវៈបង្កើតលោក បង្កើតមនុស្ស ក្នុងខ្លួនព្រះព្រហ្ម មានអាត្ម័ន រឺព្រលឹងដែលចេញពីរូបមួយទៅរូបមួយ មានកំលាំងអាត្ម័នជាព្រលឹងមនុស្សម្នាក់ អាចវិលទៅជួបព្រហ្ម័នវិញបាន ដែលជាព្រលឹងសាកល រឺមហា- ត្ម័ន ។ ព្រះពុទ្ធបដិសេធជំនឿបែបនេះ ដោយពន្យល់ ថាគ្មានអាត្ម័នរឺព្រលឹងទេ ព្រហ្ម័នក៏គ្មានដែរ។

រួមសេចក្តីមក ទ្រឹស្តីរបស់ព្រះពុទ្ធដូចបានបង្ហាញមកនេះជាទ្រឹស្តីទស្សនវិជ្ជាសំខាន់ៗដែលមានលក្ខណៈស្របនឹងស្បង់ជាច្រើន។ ទ្រឹស្តីនេះជាគំនិតបដិវត្តន៍មួយក្នុងសង្គមឥណ្ឌា ព្រោះទ្រឹស្តីរបស់ព្រះ-ពុទ្ធប្រឆាំងនឹងជំនឿក្នុងលទ្ធិព្រាហ្មណ៍។ព្រះពុទ្ធទ្រង់បានត្រិះរិះពិចារណាពីជីវិតរបស់មនុស្ស ស្វែង រកសច្ចៈដែលជាផ្លូវស្វែងរកសុខៈហើយទីបំផុតបានសំរេចដូចបំណងរបស់លោក តាមវិធីពិចារណា ពិសោធន៍អស់ជាច្រើនឆ្នាំ។ ដូចនេះទ្រឹស្តីរបស់ព្រះ- ពុទ្ធជាទស្សនវិជ្ជាមានលក្ខណៈមនុស្សនិយម ពោលគឺ មិនពិចារណាពីអាទិទេពទេ ត្រលប់មកពិចារណាពីសុខទុក្ខរបស់មនុស្សនេះវិញ ព្រមទាំងបដិសេធអាទិទេពទៀតផង។

## ចោលអន្ទ្រខហាន (បទពាក្យ៧)

អៀនដៃកន្លងមួយដងនោះ ចង់ស្ទុះចេញភ្លាមពីកន្លែង
លោកអ្នកមើលខ្ញុំហួសនឹងថ្លែង ព្រោះរឿងលុយឯងដែលនាងអាប់។
ហាងនោះថាហ៊ឹបក៏ថាបាន ម្ហូបម្ហាប៉ុន្មានគ្មានឆ្អិនស្រាប់
ទាំងនាងកាន់ចានក៏ចំណាប់ ទាំងលុយដែលអាប់ក៏ហ៊ឹបដែរ។
ខ្ញុំយកប្រាក់ខ្ញុំគ្រប់ទេតើ ម្តេចស្រីមុខស្មើលែងស្និទ្ធស្នេហ៍
ម្តេចលោកអ្នកនាងមើលខ្ញុំដែរ ខ្ញុំខ្មែរបុរាណមិនបានដឹង...។

សំរស់ជីវិត - យុន ស្រ៊ុន

## សាធុការស្នេហ៍ (ពាក្យ៧)

ថ្ងៃបាចរស្មីលើវាលស្រែ ឱទេសភាពប្រែពណ៌ដូចមាស
ហើយផ្សាយនូវបរិយាកាស រីករាយត្រចះក្រោមមេឃខៀវ។
ជ្រនៀងទន់មែកតាមវាយោ ហ្វូងគោនាំគ្នាស៊ីរញៀវ
អ្នកច្រូតដៃញាប់ក្តាប់កណ្តៀវ តែមាត់ច្រៀងជ្រៀវចំអន់គ្នា។
កង្ហាររោទិ៍ងួងចុងអំពិល លលកគតខ្ចិលហៅគូវា
អកហើរខ្ពស់ឆ្ងាយលើវេហាស៍ ឃ្លាំមើលមច្ឆាក្នុងបឹងកក់។
ជញ្ជ្រាំងកាត់ថ្មីក្លិនឈ្ងុលក្តៅ ដើមស្មៅផ្កាស្រស់ផ្តល់អន្លក់
គ្របីចាញ់ថ្ងៃចូលត្រាំភក់ ធ្មេចលក់តែមាត់ទំពារលេង។
សន្តិសោយរាជ្យក្នុងធម្មជាតិ មនោរម្យវាគទីតាំងវែង
នាំសុភមង្គលយ៉ាងស្អាតផេង បូជាគូព្រេងដែលស្នេហា។

មាលាដួងចិត្ត - នូ ហាច (១៩៧២)

## រឿងមនុស្សលោភ

កាលពីព្រេងនាយ មាននិទានថាមានកុមារីម្នាក់អាយុដប់បួនឆ្នាំម្ដាយនាងប្រើឱ្យទៅជីកដំឡូង។កុមារីនោះទៅដល់ព្រៃធំឃើញមានដំបូកមួយមានរូងជ្រៅក៏ទៅជីកដំឡូងនៅជើងដំបូកនោះ។គ្រាន់តែនាងយកចបមកជីកស្រាប់តែផ្លែវារបូតធ្លាក់ទៅក្នុងរូងនោះទៅ។ នាងមិនដឹងជាធ្វើដូចម្ដេចក៏ប្រកាសថា៖ លោកណាយកផ្លែចបឱ្យខ្ញុំបាន ខ្ញុំមិនភ្លេចគុណលោកទេ។

គ្រានោះមានខ្លាចាស់មួយដំបៅក្បាលរុយបែងដង្កូវចោះគគ្រិចចេញមកពីក្នុងព្រៃនិយាយប្រាប់នាងថា៖ នែ៎ចៅ! តាយកផ្លែចបឱ្យបាន តែតាសុំឱ្យចៅរកតែចៃឱ្យតាបានហើយ តាមិនទារគុណស្រ័យអ្វីទេ។

កុមារីពោលតបទៅខ្លាចាស់វិញថា៖ ឱ!លោកតាអើយ!ចៅសុខចិត្តទទួលធ្វើតាមសំណូមពរលោកតាឱ្យតែលោកតាជួយចៅទៅចុះ។

ខ្លាក៏ពាំផ្លែចបពីក្នុងរូងឱ្យទៅនាង ហើយបានឱ្យកុមារីរកចៃឱ្យ។ កុមារីបានបន្លាមកឆ្កឹះដង្កូវចេញពីក្នុងដំបៅក្បាលខ្លា ខ្លាចាស់បានសួរនាងថា៖ ចៅស្រីដំបៅតាស្អុយឬក្រអូប?

ពេលនោះកុមារីបានឆ្លើយប្រាប់ទៅខ្លាវិញថា៖ ក្រអូបលោកតា។ តាមពិតដំបៅនោះស្អុយខ្លាំងណាស់តែពេលណាខ្លាសួរនាងចេះតែថា ក្រអូប ។ លុះឆ្កឹះដង្កូវអស់ហើយ ខ្លាបាត់ឈឺបាត់រមាស់ ក៏និយាយប្រាប់ទៅកុមារីនោះថា៖ ចៅស្រី!ចៅយកជាលមួយមកតានឹងដាក់ដំឡូងឱ្យ។នាងបានយកជាលហុចទៅឱ្យខ្លា ខ្លាចាស់ដាក់សុទ្ធតែមាសប្រាក់ពេញជាល ចងមាត់ជាលជាប់ រួចប្រគល់ឱ្យកុមារីទាំងស្រដីប្រាប់ថា ៖ ចៅយក ជាលនេះទៅផ្ទះហៅបងប្អូនមកជុំ រួចបិទទ្វារឱ្យជិតសឹមបើកមាត់ជាល។

កុមារីលាខ្លាចាស់ដើរដល់ផ្ទះបានហៅបងប្អូនមកជុំ រួចក៏បើកមាត់ជាលឃើញសុទ្ធតែមាសនិងប្រាក់។ នាងក៏បានបែងចែកមាសប្រាក់ទាំងនោះដល់បងប្អូនគ្រប់ៗគ្នា។ លុះយូរបន្តិចមក ដំណឹងនេះលេចឮដល់ស្ត្រីមានកូនស្រីម្នាក់ដែរនៅជិតនោះ ហេតុតែប្រាថ្នាចង់បានមាសប្រាក់ច្រើនបន្ថែមទៀត ស្ត្រីនោះបានបន្ទោសកូនស្រីថា៖ ហាងឯងមើលកូនគេ គេទៅជីកដំឡូងបានសុទ្ធតែមាស និងប្រាក់យកមកចែកចាយបងប្អូនគេ ហាងឯងទៅជីកដំឡូងនឹងគេដែរ តែគ្មានបានខ្មោចអីសោះ។

ស្អែកឡើង ស្ត្រីនោះប្រើកូនស្រីឱ្យទៅជីកដំឡូងទៀត។ លុះទៅដល់ដំបូកដែលខ្លានៅ នាងនោះធ្វើជាជ្រុះផ្លែចបឱ្យដូចនាងមុន ហើយធ្វើជាស្រែកឱ្យគេជួយថា ៖ លោកណាយកផ្លែចបឱ្យខ្ញុំបាន ខ្ញុំមិនភ្លេចគុណលោកទេ។

ខ្លាឮហើយក៏យកផ្លែចបមកឱ្យ រួចបានឱ្យនាងនោះចាប់ដង្កូវចេញពីដំបៅក្បាលឱ្យ ហើយខ្លាសួរថា៖ ចៅស្រី!ដំបៅតាស្អុយឬក្រអូប? នាងនោះយកដៃម្ខាងខ្ទប់ច្រមុះរួចឆ្លើយទៅខ្លាចាស់ថា៖ ស្អុយណាស់!។ ខ្លាឮដូច្នោះក៏ប្រាប់ទៅនាងនោះថា៖ ចៅយកជាលមួយមក តានឹងដាក់មាសប្រាក់ឱ្យ។

នាងនោះត្រេកអរណាស់ស្ទុះប្រញាប់យកជាលហុចទៅឱ្យខ្លា។ខ្លាចាស់ចាប់សុទ្ធតែពស់វែកដាក់ពេញជាល ហើយប្រាប់ថា៖ ចៅយកវាទៅផ្ទះហៅបងប្អូនមកជុំ រួចបិទទ្វារឱ្យជិតសឹមបើកមាត់ជាល។ នាងនោះទៅដល់ផ្ទះបានប្រាប់ទៅម្ដាយ ម្ដាយសប្បាយចិត្តណាស់ក៏បិទទ្វារជិត រួចក៏បើកមាត់ជាលមើល ពស់វែកចេញមកចឹកស្លាប់អស់ កាលពីគ្រានោះទៅ ។



ផ្លូវល្បឿនលឿនភ្នំពេញ - ព្រះសីហនុ

( Phnom Penh - Sihanoukville Expressway )




បញ្ជរបង់ប្រាក់
ផ្លូវល្បឿនលឿនភ្នំពេញ - ព្រះសីហនុ